# ១_ព្រះរាជក្រម

## ព្រះរាជក្រមលេខ នស/រកម/០៣៩៥/០១

## យើង

## ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

ទ្រង់បានយល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំង ពីរ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយគណៈរដ្ឋមន្ត្រីយល់ព្រមផង តាមរយៈការប្រជុំពេញអង្គថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

## ប្រកាសអោយប្រើ

ច្បាប់ដែលបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងអំពីឥណទានអភិវឌ្ឍន៍ដែលបានស្រុះស្រួលគ្នា នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ១៩៩៤ រវាងព្រះរាជាណាចក្រកម្ពុជា និងសមាគមអន្តរជាតិអភិវឌ្ឍន៍ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់

# ស្តីពី

# ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍

# ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤

# រវាង

# ព្រះរាជាណាចក្រកម្ពុជា និងសមាគមអភិវឌ្ឍន៍អន្តរជាតិ

**មាត្រា ១** :ផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍ ដែលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ចីពីសមាគមអភិវឌ្ឍន៍អន្តរជាតិនូវទឹកប្រាក់ចំនួន SDR ដប់មួយលានប្រាំមួយរយពាន់ (SDR ១១.៦០០០.០០០) សមមូលនឹង USD ដប់ប្រាំពីរលានពីររយពាន់ (USD១៧.២០០.០០០) តាមឥណទានលេខ ២៦៦៤HK ដើម្បីយកមកបំរើគំរោងជំនួយការបច្ចេកទេស ។

**មាត្រា ២** : ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៥

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

បានបង្គំទូលថ្វាយ និងជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និងទី ២

ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**ព្រះរាជាណាចក្រកម្ពុជា**

ថ្ងៃទី ១៦ ធ្នូ ឆ្នាំ ១៩៩៤

**សមាគមអភិវឌ្ឍន៍អន្តរជាតិ**

**វិថីលេខ ១៨១៨ H. N. W**

**វ៉ាស៊ីនតោន ឌីស៊ី ២០៤៣៣**

**សហរដ្ឋអាមេរិក**

**យោង :** ឥណទានលេខ ២៦៦៤ KH
(គំរោងជំនួយការបច្ចេកទេស)
ផ្នែក ៩.០២ នៃល័ក្ខណ្ឌទូទៅ
ទិន្នន័យហិរញ្ញវត្ថុ និង សេដ្ឋកិច្ច

**អស់លោក ជាទីគោរព !**

អនុលោមតាមឥណទានសំរាប់ព្រះរាជាណាចក្រកម្ពុជា ត្រូវនឹងទឹកប្រាក់ជារូបិយវត្ថុផ្សេងៗគ្នាសមមូលនឹង ១១.៦០០.០០០ SRD សំរាប់គំរោងជំនួយការបច្ចេកទេស តាងនាមព្រះរាជាណាចក្រកម្ពុជា ខ្ញុំមានកិត្តិយសសូមជំរាបអស់លោកដូចតទៅ :

១–យើងយល់ច្បាស់ និង ឯកភាពថា ក្នុងគោលបំណងទាំងឡាយបានចែងក្នុងផ្នែកនៃ ៩.០២ លក្ខខ័ណ្ឌទូទៅដែលអាចអនុវត្តបានចំពោះឥណទានអភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា ត្រូវបានសំណូមពរដោយសមាគមអោយធ្វើរបាយការណ៍ថ្មី «កិច្ចសន្យាបំណុលថ្មី» (ដូចបានបញ្ជាក់ក្នុងរបាយការណ៍ ស្តីពីបំណុលរបស់ធនាគារ ចុះខែ មករា ឆ្នាំ ១៩៨៩) អោយបានមុន ៣០ថ្ងៃ បន្ទាប់ពីដំណាច់ត្រីមាស ក្នុងកំឡុងពេលដែលបំណុលបានកើតឡើងរួចហើយ និង របាយការណ៍ «ទំនាក់ទំនងក្រោមរូបភាពបំណុល» (ដូចបានបញ្ជាក់) អោយបានមុនថ្ងៃទី ៣១ មីនា នៃឆ្នាំ ។

២–សូមបញ្ជាក់ថា គ្មានកំហុសណាមួយកើតឡើងក្នុងការអនុវត្តន៍បំណុលសាធារណៈក្រៅប្រទេស ។ យើងជឿជាក់ថា ក្នុងការធ្វើឥណទាន សមាគមត្រូវផ្អែកតាមរបាយការណ៍ ឬក៏ផ្អែកតាមលិខិតនេះ ។

**ព្រះរាជាណាចក្រកម្ពុជា**

ដោយ **គាត ឈន់**

[illegible]

ឥណទានលេខ ២៦៦៤ KH

# កិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍

«គំរោងជំនួយការ—បច្ចេកទេស»

រវាង

## ព្រះរាជាណាចក្រកម្ពុជា

និង

## សមាគម អភិវឌ្ឍន៍អន្តរជាតិ

ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤

## កិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍

កិច្ចព្រមព្រៀងចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៩៤ រវាងព្រះរាជាណាចក្រកម្ពុជា ហៅកាត់ «**អ្នកខ្ចី**» និងសមាគមអភិវឌ្ឍន៍អន្តរជាតិ ហៅកាត់ «**សមាគម**» ។

«ក» អ្នកខ្ចីមានសោមនស្សរីករាយលើលទ្ធភាព និង អាទិភាព នៃគំរោងដែលបានពិពណ៌នាក្នុងកម្មវិធី ២ នៃកិច្ចព្រមព្រៀងនេះ បានស្នើសុំដល់សមាគមរួមវិភាគទានផ្នែកហិរញ្ញវត្ថុនៃគំរោង

«ខ» សមាគមបានឯកភាពពង្រីកឥណទានដល់អ្នកខ្ចីលើមូលដ្ឋានផ្សេងៗ តាមប្រការ និង លក្ខខ័ណ្ឌទាំងឡាយ ដែលបានចែងក្នុងកិច្ចព្រមព្រៀង ។

**ភាគីទាំងសងខាងបានឯកភាពដូចខាងក្រោម** :

### មាត្រា I

### លក្ខខ័ណ្ឌទូទៅ និយមន័យ

ផ្នែក ១.០១ : លក្ខខ័ណ្ឌទូទៅ អនុវត្តលើកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍របស់សមាគម ចុះថ្ងៃទី ០១-០១-៨៥ ត្រង់ឃ្លាចុងបង្អស់នៃផ្នែក ៣.០២ ដែលបានលុបចោលលក្ខខ័ណ្ឌទូទៅបង្កើតបានជាកិច្ចព្រមព្រៀងនេះទាំងស្រុង ។

ផ្នែក ១.០២ : លើកលែងតែមានសំណូមពរជាក់ស្តែងផ្សេង ។ ប្រការជាច្រើនដែលបានកំណត់ក្នុងលក្ខខ័ណ្ឌទូទៅ និង ក្នុងបុព្វកថា នៃកិច្ចព្រមព្រៀងដែលមានន័យទាក់ទងព្រមទាំងមានបន្ថែមប្រការដែលមានន័យដូចខាងក្រោម :

ក-«កអក» មានន័យថា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានបង្កើតឡើងផ្អែកតាមច្បាប់វិនិយោគទុនរបស់អ្នកខ្ចី នៃ «ព្រះរាជាណាចក្រកម្ពុជា» មានប្រសិទ្ធភាពអនុវត្តនៅថ្ងៃទី ០៥ .៨. ១៩៩៤

ខ-«កច» មានន័យថា ក្រុមប្រឹក្សាអ្នកច្បាប់របស់អ្នកខ្ចីបង្កើតឡើងអនុលោមតាមអនុក្រឹត្យរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ១៣ ចុះថ្ងៃទី ១០-៣-១៩៩៤

គ-«គណ» មានន័យថា គណៈរដ្ឋមន្ត្រីរបស់អ្នកខ្ចីបង្កើតឡើងផ្អែកតាមក្រឹត្យ ចុះថ្ងៃទី ០១-១១-១៩៩៣

ឃ-«ឆ្នាំសារពើពន្ធ» មានន័យថា រយៈពេល ១២ ខែ ទាក់ទងទៅនឹងឆ្នាំសារពើពន្ធរបស់អ្នកខ្ចីណាមួយ ដែលរយៈកាលកំណត់ចាប់ផ្តើមពី ១ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ នៃ ឆ្នាំ ប្រតិទិនទីមួយៗ

ង–«គអក» មានន័យថា គណៈកម្មាធិការបច្ចេកទេសអន្តរក្រសួងផ្នែកកែទំរង់រដ្ឋបាល បង្កើតឡើងយោងតាមអនុក្រឹត្យលេខ ២៣ ចុះថ្ងៃទី ០៩ ឧសភា ឆ្នាំ ១៩៩៤

ច–«អកច» មានន័យថា អង្គភាពកែទំរង់ច្បាប់ត្រូវបានបង្កើតឡើងដោយអ្នកខ្ចី ក្នុងក្របខ័ណ្ឌក្រុមប្រឹក្សាអ្នកច្បាប់យោងតាមប្រការដែលបានចែងក្នុងផ្នែក ៣.០៥ «ក» នៃកិច្ចព្រមព្រៀងនេះ

ឆ–«សហវ» មានន័យថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរបស់អ្នកខ្ចី

ជ–«ពណ» មានន័យថា ក្រសួងពាណិជ្ជកម្មរបស់អ្នកខ្ចី

ឈ–«យធ» មានន័យថា ក្រសួងយុត្តិធម៌របស់អ្នកខ្ចី

ញ–«ធជក» មានន័យថា ធនាគារជាតិ នៃកម្ពុជារបស់អ្នកខ្ចី

ដ–«អគគ» មានន័យថា អង្គភាពគ្រប់គ្រងគំរោង បង្កើតឡើងដោយអ្នកខ្ចី ក្នុងក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុលោមតាមប្រកាសលេខ ២៨៩ ប្រក ចុះថ្ងៃទី ២៨ វិច្ឆិកា ១៩៩៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឋ–«ភ្នាក់ងារគំរោង» មានន័យថា ក្រសួងស្ថាប័ន និង ភ្នាក់ងារនានារបស់អ្នកខ្ចី ដែលមានភារកិច្ចជួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុក្នុងការអនុវត្តន៍គំរោង ។ ភ្នាក់ងារគំរោងទាំងនេះត្រូវផ្អែកតាមឧបសម្ព័ន្ធក្នុងកម្មវិធី ២ របស់កិច្ចព្រមព្រៀងនេះ ។

ឌ–ផែនការអនុវត្តន៍គំរោងមានន័យថា ផែនការសំរាប់អនុវត្តគំរោងរបស់អ្នកខ្ចី ហើយត្រូវបានផ្អែកតាមក្នុងផ្នែក ៣.០១ (២) និង មានចែងក្នុងកម្មវិធី ៥ ក្នុងកិច្ចព្រមព្រៀង ។

ឍ–«គណនីពិសេស» មានន័យថា ជាគណនីដែលបានចែងក្នុងផ្នែក ២.០២ (២) របស់កិច្ចព្រមព្រៀង ។

## មាត្រា II

## ឥណទាន

ផ្នែក ២.០១ : សមាគមឯកភាពផ្តល់អោយអ្នកខ្ចី លើលក្ខខ័ណ្ឌ និង ប្រការទាំងឡាយដែលបានចែង ឬ តាមកិច្ចព្រមព្រៀងឥណទានអភិវឌ្ឍន៍នេះ លើចំនួនទឹកប្រាក់មួយជារូបិយវត្ថុផ្សេងៗគ្នាសមមូលនឹងចំនួន ដប់មួយលានប្រាំមួយរយពាន់

SDR «១១,៦០០,០០០» ។

ផ្នែក ២.០២(ក) : ចំនួនទឹកប្រាក់នៃឥណទាន ដែលអាចដកគណនីឥណទាន អនុលោមតាមប្រការទាំងឡាយ ដែលបានចែងក្នុងកិច្ចព្រមព្រៀងឥណទាន សំរាប់យកមកចំណាយ ឬ ត្រូវបានចំណាយក្រោយពីបានឯកភាពពីសមាគមត្រូវគោរពតាម តំលៃសមហេតុផល របស់ទំនិញ សេវា ដែលត្រូវការរបស់គំរោងដូចបានចែងក្នុងកម្មវិធី ២ នៃកិច្ចព្រមព្រៀងព្រមទាំងត្រូវបានផ្តល់ហិរញ្ញប្បទានចេញពីចំនួនទឹកប្រាក់ នៃឥណទាន ។

(ខ) : ដើម្បីគោលដៅនៃគំរោង អ្នកខ្ចីត្រូវបើកគណនីពិសេសមួយ ជាដុល្លារអាមេរិកនៅធនាគារជាតិនៃកម្ពុជា លើលក្ខខ័ណ្ឌដ៏ប្រសើររបស់សមាគមដោយប្រព្រឹត្តទៅសមស្របរួមការពារទប់ទល់ការប៉ះប៉ូវរឹបអូស ។ ប្រាក់តំកល់ និងការទូទាត់តាមរយៈគណនីពិសេសនេះនឹងប្រព្រឹត្តទៅត្រឹមត្រូវតាមខ្លឹមសារដែលបានចែងក្នុងកម្មវិធី ៤ នៃកិច្ចព្រមព្រៀងនេះ ។

ផ្នែក ២.០៣ : កាលបរិច្ឆេទបញ្ចប់ឥណទានត្រូវបានគ្រោង នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០១ ឬ អាចក្រោយកាលបរិច្ឆេទនេះ យោលទៅលើសមាគម ។ សមាគមនឹងជូនដំណឹងស្តីពី កាលបរិច្ឆេទថ្មីដល់អ្នកខ្ចីអោយបានឆាប់រហ័ស ។

ផ្នែក ២.០៤(ក) : អ្នកខ្ចីត្រូវបង់ជូនសមាគម នូវបន្ទុកកិច្ចសន្យាតាមអត្រាមួយដែលកំណត់ដោយសមាគមលើចំនួនទឹកប្រាក់នៃឥណទានដែលមិនទាន់បានដកប្រើនៅថ្ងៃទី ៣០ ខែ មិថុនា រៀងរាល់ឆ្នាំ ក៏ប៉ុន្តែអត្រានោះមិនអោយលើសពីពាក់កណ្តាល នៃមួយភាគរយក្នុងមួយឆ្នាំ ។

(ខ) : បន្ទុកកិច្ចសន្យាចាប់គិតពី ៦០ ថ្ងៃ (i) បន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមានទៅទល់នឹងកាលកំណត់មួយដែលចំនួននោះ ត្រូវបានដកដោយអ្នកខ្ចីពីគណនីឥណទាន ឬត្រូវបានលុបចោល ។ (ii) និង តាមអត្រាកំណត់ក្នុងថ្ងៃទី ៣០ មិថុនា ក្រោយពេលកិច្ចព្រមព្រៀងចូលជាធរមានភ្លាមៗ ឬ តាមអត្រាផ្សេងទៀតជាបន្តបន្ទាប់ យោងតាមកថាខ័ណ្ឌ ក ខាងលើ ។ អត្រាដែលកំណត់ នៅថ្ងៃទី ៣០ មិថុនា នៃឆ្នាំនីមួយៗ ត្រូវបានចាប់អនុវត្តពីកាលបរិច្ឆេទទូទាត់បន្ទាប់នៃឆ្នាំនោះ ដូចដែលបានបញ្ជាក់ក្នុងផ្នែក ២.០៦ នៃកិច្ចព្រមព្រៀងនេះ។

(គ): អ្នកខ្ចីត្រូវទូទាត់សងបន្ទុកកិច្ចសន្យា (i) តាមទីកន្លែងដែលសមាគម

សំណូមពរ (ii) ដោយគ្មានព្រំដែនលើប្រភេទចាប់បង្ហំណាមួយ (iii) ហើយដោយរូបិយប័ណ្ណជាក់លាក់ក្នុងកិច្ចព្រមព្រៀងនេះ ដើម្បីគោលបំណងក្នុងផ្នែក ២.០៤ នៃលក្ខខ័ណ្ឌទូទៅទាំងឡាយ ឬ រូបិយប័ណ្ណផ្សេងទៀតដែលយកជាការបាន ឬ ជ្រើសរើសតាមប្រភេទសមស្របតាមខ្លឹមសារដែលបានចែងក្នុងផ្នែកនោះ ។

ផ្នែក ២.០៥ : អ្នកខ្ចី ត្រូវទូទាត់សងទៅសមាគម នូវបន្ទុកសេវាមួយតាមអត្រា ៣ ភាគ ៤ នៃ ១% ក្នុងមួយឆ្នាំលើចំនួនប្រាក់ដើម នៃឥណទានដែលបានដក និងចំនួនកំពុងប្រព្រឹត្តទៅបន្តបន្ទាប់ ។

ផ្នែក ២.០៦ : បន្ទុកកិច្ចសន្យា និង បន្ទុកសេវា ត្រូវទូទាត់ពីរដងក្នុងមួយឆ្នាំ ពោលគឺនៅថ្ងៃទី ០១ ខែ ឧសភា ម្តង និងនៅថ្ងៃទី ០១ ខែ វិច្ឆិកា ម្តងរៀងរាល់ឆ្នាំ ។

ផ្នែក ២.០៧ : យោងតាមកថាខ័ណ្ឌ «ខ» និង «គ» ខាងក្រោម អ្នកខ្ចីត្រូវទូទាត់សងវិញចំពោះប្រាក់ដើម នៃឥណទានពីរដងក្នុងមួយឆ្នាំ នៅថ្ងៃទី ០១ ឧសភា ម្តងនិង ថ្ងៃទី ០១ វិច្ឆិកា ម្តងជារៀងរាល់ឆ្នាំ ដោយចាប់ផ្តើមពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៥ ព្រមទាំងបញ្ចប់នៅថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០៣៤ ។ ការទូទាត់ តាមលើកនីមួយៗ រួមទាំងចាប់ពីដើមដំបូង ពោលគឺថ្ងៃទី ០១ ឧសភា ឆ្នាំ ២០១៤ ត្រូវជា ១ ភាគរយ លើចំនួនប្រាក់ដើម ។ ហើយក្រោយមកការទូទាត់តាមលើកនីមួយៗ ត្រូវកំណត់ ២ ភាគរយ លើចំនួនប្រាក់ដើម ។

(ខ): ពេលណា (i) ផលិតផលជាតិដុលក្នុងម្នាក់ៗ ដែលកំណត់ដោយសមាគមលើសពីប្រាំពីររយកៅសិប «៧៩០» ដុល្លារអាមេរិក គិតតាមតំលៃស្មើរ ភាពនាឆ្នាំ ១៩៨៥ សំរាប់ ៥ ឆ្នាំ បន្តបន្ទាប់ ហើយ (ii) ធនាគារចាត់ទុកអ្នកខ្ចី «អ្នកមានលទ្ធភាពសង» សមាគមអាចកែសំរួលលើប្រការទូទាត់តាមដំណាក់ៗ ក្រោមកថាខ័ណ្ឌខាងលើ តំរូវអោយអ្នកខ្ចីទូទាត់ជាពីរដងលើចំនួនដែលត្រូវទូទាត់តាមលើកនីមួយៗ រហូតដល់ឥណទានទាំងមូលត្រូវទូទាត់រួចរាល់ ។ បើសិនជាមានសំណូមពរពីអ្នកខ្ចី សមាគមអាចពិនិត្យកែសំរួលឡើងវិញ លើករណីខ្លះៗ ឬ ទាំងអស់លើចំនួននៃជំហានទូទាត់បែបនេះ ការសងការតាមអត្រាប្រចាំឆ្នាំ បានឯកភាពជាមួយសមាគមលើចំនួនប្រាក់ដើម នៃឥណទាន ដែលបានដក និង ចំនួនកំពុងប្រព្រឹត្តទៅ

ជាបន្តបន្ទាប់ ។ ក្នុងការវិនិច្ឆ័យ របស់សមាគម ការពិនិត្យឡើងវិញ នឹងមិនផ្លាស់ប្តូរកត្តាសំខាន់ៗ ដែលទទួលបានក្រោមការកែសំរួលទូទាត់ គួសបញ្ជាក់ខាងលើ ។

(គ): បើសិនជានៅពេលណាមួយ បន្ទាប់ពីមានការកែសំរួលលើលក្ខខ័ណ្ឌតាម កថាខ័ណ្ឌ «ខ» ខាងលើ និង ក្រោយពេលក្រុមប្រឹក្សាភិបាលធនាគារបាន ពិចារណា ហើយសមាគមកំណត់ថា បើលក្ខខ័ណ្ឌសេដ្ឋកិច្ចរបស់អ្នកខ្ចីធ្លាក់ យ៉ាងខ្លាំងនោះ យោងតាមសំណើរបស់អ្នកខ្ចី ធនាគារអាចកែលំអលក្ខខ័ណ្ឌ ដើម ក្នុងការសងអនុលោមតាមកម្មវិធីទូទាត់តាមលើកនីមួយៗ នៃកថាខ័ណ្ឌ (គ) ខាងលើ ។

ផ្នែក ២.០៨ : រូបិយវត្ថុ នៃសហរដ្ឋអាមេរិក គឺត្រូវបានបញ្ជាក់ សំរាប់គោលបំណងនានានៃ ផ្នែក៤.០២ នៃលក្ខខ័ណ្ឌទូទៅ ។

## មាត្រា III

## ប្រតិបត្តិគំរោង

ផ្នែក ៣.០១ (ក): អ្នកខ្ចីប្រកាសនូវកិច្ចសន្យារបស់ខ្លួន ចំពោះគោលដៅ នៃគំរោងនេះ ឆ្លងតាម ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ភ្នាក់ងារអនុវត្តគំរោងជាមួយនឹងការ យកចិត្តទុកដាក់ ផ្តល់ផលប្រយោជន៍រៀបចំ សមស្របលើការងាររដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស សំភារៈ សេវាសាធារណៈ ដើម្បីឆ្លើយតប បានទាន់ពេលវេលា ។

(ខ): អ្នកខ្ចី ត្រូវអនុវត្តសមស្របតាមផែនការអនុវត្តគំរោង ដូចបានចែងក្នុងកម្ម វិធី ៥ នៃកិច្ចព្រមព្រៀងដោយគ្មានកំណត់ព្រំដែន អនុលោមតាមកថាខ័ណ្ឌ «ក» នៃផ្នែកនេះ លើកលែងតែមានការព្រមព្រៀងរវាងអ្នកខ្ចី និងសមាគម។

ផ្នែក ៣.០២ : អនុលោមតាមសេចក្តីដែលបានចែងក្នុងមាត្រា ៩ នៃលក្ខខ័ណ្ឌទូទៅ អ្នកខ្ចី ត្រូវ :

(ក): រៀបចំ និង ផ្គត់ផ្គង់ដល់សមាគមអោយបានមុន ៦ ខែបន្ទាប់ពីកាលបរិច្ឆេទ បន្ទាប់ណាមួយទៀតដែលបានឯកភាពគ្នារវាងអ្នកខ្ចី និង សមាគមនូវផែន ការចំណុចដៅជាលំអិតតាមសំណើ សមហេតុផលរបស់សមាគម សំរាប់កិច្ច

ប្រតិបត្តិគំរោងទៅអនាគត ។

(ខ): បង្កលក្ខណៈដល់សមាគមនូវឱកាសសមស្របមួយក្នុងការប្តូរទស្សនៈជាមួយអ្នកខ្ចី លើផែនការខាងលើ

(គ): អនុវត្តផែនការដោយត្រឹមត្រូវ និងមានប្រសិទ្ធភាពយោលទៅតាមបទពិសោធន៍ជាក់ស្តែង និង ស្របតាមគោលបំណងរបស់ធនាគារ

ផ្នែក៣.០៣(ក): ជានិច្ចជាកាល រហូតដល់ចុងបញ្ចប់នៃគំរោង អ្នកខ្ចីត្រូវរក្សា អគគ ក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងកំលាំងមនុស្ស និង សំភារៈចាំបាច់ ធ្វើអោយប្រាកដថា អគគ ត្រូវបានដឹកនាំដោយអ្នកសំរបសំរួលគំរោង ដោយមានសមត្ថភាព និង ទទួលយកបានដោយសមាគម ហើយមន្ត្រីដែលបំរើការងារទៀតសោត ត្រូវមានសមត្ថភាពជាមួយបរិមាណសមរម្យហើយផ្តល់បានឆាប់រហ័ស នូវរាល់មូលនិធិគ្រឿងសំភារៈ សេវាផ្សេងៗទៀត ដែលត្រូវការដើម្បីអោយ អគគ បំពេញភារកិច្ចមុខងារ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ។

(ខ): អគគ ជាបឋមត្រូវតែយកចិត្តទុកដាក់ធ្ងន់លើការងារគ្រប់គ្រងជាទូទៅ រដ្ឋបាល កិច្ចសំរបសំរួលអនុវត្តគំរោងរួមទាំងការផ្គត់ផ្គង់រាល់ទំនិញសេវាកម្មការងារ ។ល។ តាមសំណូមពរ ។

(គ): អ្នកខ្ចីត្រូវបង្កលក្ខណៈដល់ អគគ ក្នុងការរៀបចំ និង ផ្គត់ផ្គង់ដល់សមាគមលើការសើរើពិនិត្យអោយបានមុនថ្ងៃទី ៣០ មិថុនា និង ៣១ ធ្នូ ក្នុងឆ្នាំសារពើពន្ធនីមួយៗ លើរបាយការណ៍ប្រចាំឆ្នាំ ស្តីពីដំណើរការអនុវត្តន៍គំរោងរបស់អ្នកខ្ចី ព្រមទាំងរាល់ការចំណាយទាក់ទងទៅនឹងគំរោងនេះ ។

ផ្នែក ៣.០៤ : សំរាប់គោលបំណងនៃការអនុវត្តន៍ត្រង់ភាគ ក.១ នៃគំរោង អ្នកខ្ចីត្រូវ :

(ក): តែងតាំងមន្ត្រីទាំងឡាយដែលត្រូវរួមសហការ លើលក្ខខ័ណ្ឌទាំងឡាយដែលព្រមព្រៀងគ្នា ដោយពេញចិត្តរបស់សមាគម ក្នុងកិច្ចសហការ នៅពេលអ្នកជំនួយការមកដល់ ឬការប្រគល់នូវប្រព័ន្ធគ្រប់គ្រងពត៌មានវិទ្យា និងធ្វើអោយប្រាកដថា ភ្នាក់ងារគំរោងដែលអនុវត្តនូវមុខសញ្ញាផែនការការងារខ្លួនគឺយោង លើកម្មវិធី ការងារឆ្នាំ នៃផែនការក្រោមផែនការអនុវត្តន៍គំរោង និងបន្ទាប់មកទៀតត្រូវសើរើពិនិត្យ និង តាមដានជាប់លើផែនការនេះ ដោយពិគ្រោះយោបល់ជាមួយសមាគម អោយបានមុនថ្ងៃទី ៣១ មិថុនា

រៀងរាល់ឆ្នាំសារពើពន្ធ ដោយចាប់ផ្ដើមពីពេលបញ្ចប់ឆ្នាំសារពើពន្ធនាថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៩៥ ។

ផ្នែក ៣.០៥ : សំរាប់គោលបំណងនៃការអនុវត្តទំព្រង់ភាគ ខ នៃគំរោងអ្នកខ្ចីត្រូវ :(ក) បង្កើត និង រក្សារហូតដល់ពេលបញ្ចប់ នៃគំរោងនូវអង្គភាពកែទម្រង់ច្បាប់ (អកច ក្រោមនិរាទ កច) អោយបានមុនថ្ងៃទី ៣០ មិថុនា ឆ្នាំ ១៩៩៥ ។ ការបង្កើតអង្គភាពនេះ ត្រូវសមស្របទៅនឹងប្រការទាំងឡាយ និង ប្រភពធនធានដែលសមាគមពេញចិត្ត ត្រូវបានដឹកនាំជាប្រចាំដោយទីប្រឹក្សាអ្នកច្បាប់ ដែលពោរពេញទៅដោយបទពិសោធន៍ និង បានទទួលជំនួយគាំទ្រយ៉ាងមុតមាំពីមន្ត្រីស្ទាត់ជំនាញខាងច្បាប់មួយចំនួនសមស្រប (ខ) រៀបចំអនុម័តរបាយការណ៍ជាផ្លូវការស្ដីពីច្បាប់សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ព្រមទាំងបទបញ្ញាផ្សេងៗ ដែលត្រូវផ្សព្វផ្សាយក្នុងកំឡុងពេលពីឆ្នាំ ១៩៩៥ ដល់ ១៩៩៨ សំរាប់អភិវឌ្ឍន៍នូវ មូលដ្ឋានសេដ្ឋកិច្ចទីផ្សារ សកម្មភាពវិស័យឯកជន ។

ផ្នែក ៣.០៦ : ដោយគោរពទៅតាមកម្មវិធីសិក្សា បំពាក់បំប៉នដែលត្រូវអនុវត្តក្រោម ភាគ គ នៃគំរោង អ្នកខ្ចីត្រូវផ្ដល់ដល់សមាគម ក្នុងការអនុមតិមុនគេ :(ក)ប្រការជាមូលដ្ឋានទាំងឡាយក្នុងការអនុវត្តន៍ផ្ដល់ហិរញ្ញប្បទាន និង ត្រួតពិនិត្យតាមដាន ការសិក្សាខាងលើ និង (ខ) ប្រការជាមូលដ្ឋាន នៃកម្មវិធីបណ្ដុះបណ្ដាល ទាំងឡាយព្រមទាំងកម្មវិធីសំរាប់ការអនុវត្តន៍របស់វា និង លក្ខណៈសម្បត្តិជ្រើសរើសមុខសញ្ញាអោយចូលក្នុងវគ្គបណ្ដុះបណ្ដាលនេះ ។

ផ្នែក ៣.០៧ : គ្មានកំណត់ព្រំដែន អនុលោមតាមខ្លឹមសារទាំងឡាយ ដែលបានចែងក្នុងលក្ខខណ្ឌទូទៅ នៃកិច្ចព្រមព្រៀង :(ក) លើមូលដ្ឋាននៃប្រការទាំងឡាយដែលសមាគមទទួលយល់ព្រម អោយបានមុនថ្ងៃទី ៣០ មិថុនា ១៩៩៧ អ្នកខ្ចីត្រូវដឹកនាំវគ្គយល់ដឹងស្ដីពីការសើរើពិនិត្យឡើងវិញ លើលទ្ធផលនៃការអនុវត្តន៍គំរោងរបស់អ្នកខ្ចី និង (ខ) ចាប់អារម្មណ៍ដល់យោបល់ណែនាំរបស់សមាគម ក្រោយពីការសើរើពិនិត្យអ្នកខ្ចីត្រូវតែអនុវត្តអោយបានត្រឹមត្រូវ និង ប្រកបដោយប្រសិទ្ធភាព ព្រមទាំងចាត់វិធានការចាំបាច់ដើម្បីឈានទៅសំរេច អោយបានជោគជ័យទាំងស្រុង ចំពោះគោលដៅនៃគំរោង ។

ផ្នែក ៣.០៨ : លើកលែងតែមានការព្រមព្រៀងដោយឡែកពីសមាគម ការផ្គត់ផ្គង់ទំនិញការ ងារសេវាសិក្សាគំរោង ហើយត្រូវបានផ្តល់ហិរញ្ញប្បទានដោយឥណទានត្រូវគោរពតាមវិធានសារ[illegible]ដែលបានចែងក្នុងកម្មវិធី ៣ នៃកិច្ចព្រមព្រៀង។

## មាត្រា IV

## ហិរញ្ញវត្ថុ

ផ្នែក ៤.០១ (ក): អ្នកខ្ចីត្រូវរក្សា ឬ បង្គាប់[illegible]អោយមានសៀវភៅ បញ្ជីការដោយបានច្បាស់លាស់ និង ឆ្លុះបញ្ចាំងអោយបានត្រឹមត្រូវ ជាមួយប្រតិបត្តិការជាក់ស្តែងទាំងចំណាយ និង ចំណូល ដោយគោរពតាមគំរោងរបស់នាយកដ្ឋាន ភ្នាក់ងារដែលទទួលខុសត្រូវក្នុងការអនុវត្តន៍គំរោង ឬ ផ្នែកណាមួយ នៃគំរោង

(ខ): អ្នកខ្ចីត្រូវ (i) កត់ត្រា និង បញ្ជីការផ្នែក តាមកថាខណ្ឌ «ក» នៃផ្នែក[illegible] ក្នុងនោះក៏ត្រូវធ្វើដូចគ្នាដែរ ចំពោះគណនីពិសេសក្នុងឆ្នាំសារពើពន្ធនីមួយៗ យោលទៅតាមគោលការណ៍ជំរះបញ្ជីសមស្រប ធ្វើឡើងដោយក្រុមជំរះបញ្ជីដែលមានការយល់ព្រមដោយសមាគមផង ។ (ii) ផ្តល់អោយសមាគមអោយបានឆាប់រហ័ស ធ្វើយ៉ាងណាកុំអោយលើសពី ៦ ខែ បន្ទាប់ពីបញ្ចប់ឆ្នាំនីមួយៗ នូវឯកសារបញ្ជាក់របាយការណ៍ របស់អ្នកជំរះបញ្ជី ត្រូវពិនិត្យតាមសំណូមពរសមហេតុផលរបស់សមាគម ។

(iii) ផ្តល់ដល់សមាគមនូវព័ត៌មានទាក់ទងទៅនឹងកិច្ចបញ្ជីការ និង ការជំរះបញ្ជីគណនីនានាតាមសំណើរបស់សមាគម ។

(គ): ចំពោះរាល់ការចំណាយដែលដកពីគណនីឥណទានពីត្រូវបានធ្វើឡើងមូលដ្ឋាននៃសេចក្តីប្រកាស អ្នកខ្ចីត្រូវ (i) រក្សាបង្កាន់ដៃ រក្សាសៀវភៅអនុ[illegible]តាមកថាខណ្ឌ «ក» នៃផ្នែកនេះ ដើម្បីកត់ត្រា និង ឆ្លុះបញ្ចាំង[illegible] [illegible] ។ (ii) [illegible] [illegible] [illegible] [illegible] ជាតិ និង ដាក់[illegible]ទៀត ជាសក្ខីប័ត្រចំណាយ ។ (iii)

ជួយធ្វើជា តំណាងអោយសមាគម ដើម្បីត្រួតពិនិត្យលើការកត់ត្រាទាំងអស់នេះ ។ (iv) ធានាការកត់ត្រាគណនីទាំងនេះ ត្រូវបញ្ចូលទាំងការជំរះបញ្ជីក្នុងឆ្នាំ អនុលោមតាមកថាខ័ណ្ឌ «ខ» នៃផ្នែកនេះ ព្រមទាំងរបាយការណ៍នៃការជំរះបញ្ជីនេះ ត្រូវវែកញែកយោបល់របស់អ្នកជំរះបញ្ជីខាង លើ ចំណែកឯរបាយការណ៍ ចំណាយដែលផាក់ជូនក្នុងកំឡុងឆ្នាំសារពើពន្ធរួមជាមួយនឹងទំរង់ការ និង ការត្រួតពិនិត្យផ្នែកក្នុងទាក់ទង និងការរៀបចំរបស់ខ្លួនអាចទុកចិត្តនិងគាំទ្រដល់ការដកប្រាក់ចេញ ។

## មាត្រា V

## កាលបរិច្ឆេទដាក់អោយអនុវត្ត និង កាលកំណត់បញ្ចប់

ផ្នែក ៥.០១ : រយៈពេល ១២០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលកិច្ចព្រមព្រៀងត្រូវបានបញ្ជាក់ច្បាស់លាស់ចំពោះគោលដៅ នៃផ្នែក ១២.០៤ នៃលក្ខខ័ណ្ឌទូទៅ ។

ផ្នែក ៥.០២ : កាតព្វកិច្ចរបស់អ្នកខ្ចី ផ្នែកតាមមាត្រា ៣ និង ៤ នៃកិច្ចព្រមព្រៀងនេះ ត្រូវបញ្ឈប់នៅកាលបរិច្ឆេទដែលកិច្ចព្រមព្រៀងបានបញ្ចប់ឬមួយនៅកាលបរិច្ឆេទម្ភៃ (២០)ឆ្នាំ ក្រោយកាលបរិច្ឆេទកិច្ចព្រមព្រៀងនេះ ដែលជាកាលកំណត់ឆាប់បំផុត ។

## មាត្រា VI

## តំណាង អ្នកខ្ចី អាស័យដ្ឋាន

ផ្នែក ៦.០១ : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបានជ្រើសរើសជាតំណាងអ្នកខ្ចី សំរាប់គោលបំណងនៃផ្នែក ១១.០៣ នៃលក្ខខ័ណ្ឌទូទៅ ។

ផ្នែក ៦.០២ : អាស័យដ្ឋានខាងក្រោមត្រូវបានបញ្ជាក់ច្បាស់សំរាប់គោលបំណងផ្នែក ១១.០១ នៃលក្ខខ័ណ្ឌទូទៅ ។

ចំពោះភាគីអ្នកខ្ចី : ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

តេឡិច :(៥៨៣)១៧៧០១០១ CMPP

ចំពោះសមាគម : សមាគមអភិវឌ្ឍន៍អន្តរជាតិ

វិថីលេខ : ១៨១៨ H,N.W

វ៉ាស៊ីនតោន, ឌីស៊ី . ២០៤៣៣

សហរដ្ឋអាមេរិក

Telex :

cable Address

INDEVAS ២៤៨៤២៣

(RCA),

វ៉ាស៊ីនតោន, ឌីស៊ី ៨២៩៨៧

(FTCC),

៦៤១៤៥

(WUI)or

១៩៧៦៨៨

(TRT).

ដើម្បីជាសក្ខីភាពភាគីទាំងពីរ ដែលកំពុងអនុវត្តតាមរយៈតំណាងដែលបានទទួលការអនុញ្ញាតសិទ្ធិត្រឹមត្រូវរបស់ភាគីនីមួយៗ បានបង្កលក្ខណៈអោយកិច្ចព្រមព្រៀងឥណទានបានចុះហត្ថលេខារៀងៗ ខ្លួននៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃ. ខែ. ឆ្នាំ ដែលបានចែងពីដំបូងខាងលើ ។

**ព្រះរាជាណាចក្រកម្ពុជា**

ដោយ តំណាងមានសមត្ថកិច្ច **គាត ឈន់**

**សមាគមអភិវឌ្ឍន៍អន្តរជាតិ**

ដោយ តំណាងមានសមត្ថកិច្ច **អាណូ ម៉ារីណា**

* * *

## កម្មវិធី១

ការបែកប្រាក់ឥណទាន

១– តារាងខាងក្រោមចែងអំពីប្រភេទមុខចំណាយដែលត្រូវបានហិរញ្ញប្បទានពីទឹកប្រាក់នៃឥណទានការផ្តល់ចំនួនប្រាក់ នៃឥណទានសំរាប់ប្រភេទមុខចំណាយនីមួយៗ និង ភាគរយនៃមុខចំណាយ ដែលត្រូវបានហិរញ្ញប្បទានក្នុងប្រភេទនីមួយៗ

| | ចំនួនប្រាក់ឥណទាន ត្រូវផ្តល់ | ភាគរយនៃចំណាយ ត្រូវហិរញ្ញប្បទាន |
|---|---|---|
| **ប្រភេទ** | **សមមូលជា SDR** | |
| (១) សាងសង់ ក្នុងផ្នែក (២) នៃគំរោង | ៥២២.០០០ | ៩០% |
| (២) ទំនិញ | ៨៤៧.០០០ | ១០០%នៃចំណាយក្រៅប្រទេស<br>១០០%នៃចំណាយក្នុងស្រុក (បរិយាទានផលិតកម្ម)<br>និង ៩០%ចំណាយក្នុងប្រទេសសំរាប ទំនិញផ្សេងៗទៀតក្នុងស្រុក។ |
| (៣) សេវាពិគ្រោះ | ៧.៩៥៣.០០០ | ១០០% |
| (៤) បណ្តុះបណ្តាល | ៩៧៨.០០០ | ១០០% |
| (៥) ការសិក្សាស្រាវជ្រាវ | ៧៨២.០០០ | ១០០% |
| (៦) ត្រៀមបំរុង | ៥១៨.០០០ | |

**សរុប** ១១.៦០០.០០០

**២–សំរាប់គោលបំណងនៃកម្មវិធី ១ :**

ពាក្យ «ចំណាយក្រៅប្រទេស» មានន័យថាចំណាយជារូបិយវត្ថុរបស់ប្រទេសណាមួយក្រៅពីប្រទេសអ្នកខ្ចីសំរាប់ទិញ ឬសេវាដែលផ្គត់ផ្គង់ពីទឹកដីនៃប្រទេសណាមួយក្រៅពីប្រទេស អ្នកខ្ចី និង

ពាក្យ «ចំណាយក្នុងប្រទេស» មានន័យថា ចំណាយជារូបិយវត្ថុ របស់ប្រទេសអ្នកខ្ចីសំរាប់ទំនិញ ឬ សេវា ដែលផ្គត់ផ្គង់ពីទឹកដីនៃប្រទេសអ្នកខ្ចី ។

៣–ដោយបដិបញ្ញត្តិចំពោះកថាខ័ណ្ឌ ១ ខាងលើការដកប្រាក់សំរាប់ទូទាត់ចំណាយពុំអាចប្រព្រឹត្តទៅបានមុនកាលបរិច្ឆេទ នៃកិច្ចព្រមព្រៀងនេះទេ ។

៤–សមាគមអាចតំរូវអោយដកប្រាក់ពីគណនីឥណទាន ដែលធ្វើឡើងដោយផ្អែកលើមូលដ្ឋានបញ្ជីសំរង់ចំណាយតាមកិច្ចសន្យាទាំងឡាយ :

តំលៃការងារមិនហួសសមមូលមួយរយពាន់ដុល្លារ (១០០.០០០)

ទំនិញមិនហួសសមមូល ហាសិបពាន់ដុល្លារ (៥០.០០០)

ក្រុមហ៊ុនពិគ្រោះមិនហួសសមមូលមួយរយពាន់ដុល្លារ (១០០.០០០)

អ្នកពិគ្រោះជាបុគ្គលមិនហួសសមមូលហាសិបពាន់ដុល្លារ (៥០.០០០) និងគ្រប់តំលៃបណ្ដុះបណ្ដាលទាំងអស់ក្រោមកាលកំណត់ និង លក្ខខ័ណ្ឌកាលណាសមាគមបញ្ជាក់សេចក្ដី ប្រកាសជូនអ្នកខ្ចី ។

## កម្មវិធី២

## ពិពណ៌នាអំពីគំរោងការ

គោលដៅនៃគំរោងការ គឺជួយអោយអ្នកខ្ចីបង្កើត និងអនុវត្តការកែទំរង់ស្ថាប័នដើម្បី (i) កែលំអការងារគ្រប់គ្រងហិរញ្ញវត្ថុផ្នែកសាធារណៈ និង (ii) បង្កើតបរិដ្ឋានទីផ្សារមួយ សំរាប់អភិវឌ្ឍន៍ឯកជន ។

គំរោងការរួមមានផ្នែកដូចតទៅ ដែលអាចកែប្រែបាន កាលណាអ្នកខ្ចី និង សមាគមយល់ព្រមជាមួយគ្នាថា នឹងឈានដល់គោលដៅទាំងនោះជាបន្ទាន់ :

**ផ្នែក ក: ការងារគ្រប់គ្រងផ្នែកសាធារណៈ**

១–ផ្ដល់ជំនួយការបច្ចេកទេស ដើម្បីជួយជ្រោមជ្រែង ដល់អ្នកខ្ចី ក្នុងការអនុវត្តនីតិវិធីកែទំរង់ការងារគ្រប់គ្រង ផ្នែកសាធារណៈដោយ:

(ក) ពង្រឹងសមត្ថភាព ស្ថាប័នរបស់អ្នកខ្ចី តាមរយៈការត្រួតពិនិត្យចំណាយសាធារណៈ ដោយពង្រីកសមត្ថភាពចាំបាច់ការវិភាគម៉ាក្រូសេដ្ឋកិច្ច និងរៀបចំថវិកាជាតិ និងខេត្ត–ក្រុងប្រចាំឆ្នាំ (ii) សមាសធាតុកម្ម នីតិវិធីគ្រប់គ្រងថវិកា ចូលក្នុងវដ្ដនៃផែនការកម្មវិធីថវិកា (iii) កែលំអប្រព័ន្ធអនុវត្ត ថវិកា ធ្វើអធិការកិច្ច និង ត្រួតពិនិត្យ (iv) អភិវឌ្ឍន៍ប្រព័ន្ធមួយសំរាប់អធិការកិច្ច ប្រតិបត្តិការរតនាគារ និង រៀបចំបញ្ជីវិភាគប្រចាំខែ (v) បង្កើតប្រព័ន្ធព្យាករណ៍ប្រចាំខែស្ដីពីចំណូលចំណាយរតនៈវត្ថុ (vi) បង្កើតចេញវិធានរដ្ឋបាល

និងគណនេយ្យ ព្រមទាំងនីតិវិធីប្រមូលចំណូល និងកិច្ចប្រតិបត្តិការ ចំណាយ(vii) ពង្រឹកនីតិក្របខ័ណ្ឌ និង បទបញ្ញាចំពោះគណនេយ្យសាធារណៈ (viii) កែលំអប្រមូល កិច្ចប្រតិបត្តិការគណនេយ្យ នៅកំរិតមួយនៅតាមខេត្ត–ក្រុង និង (ix) បង្កើតប្រព័ន្ធ គណនេយ្យមួយ សំរាប់កិច្ចប្រតិបត្តិការរូបិយវត្ថុបរទេស ។

(ខ) ពង្រឹងសមត្ថភាពស្ថាប័ន របស់អ្នកខ្ចីដើម្បីធ្វើផែនការកម្មវិធី និងគ្រប់គ្រងវិនិយោគសាធារណៈដោយ (i) បង្កើតអង្គភាពថវិកា វិនិយោគសាធារណៈ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ii) អភិវឌ្ឍន៍ ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ តាមបែបពត៌មានវិទ្យា នៅអង្គភាពដែលបាន និយាយខាងលើនេះ (iii) បង្កើតនីតិវិធី និង បទបញ្ញាសំរាប់គ្រប់គ្រងវិនិយោគសាធារណៈ និងត្រួតពិនិត្យគំរោងការ (iv) បង្កើតសមត្ថភាពជាយុទ្ធសាស្ត្រ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិង (v) អភិវឌ្ឍន៍ សមត្ថភាពវិភាគម៉ាក្រូសេដ្ឋកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

(គ) ពង្រឹងសមត្ថភាពស្ថាប័នរបស់អ្នកខ្ចី សំរាប់គ្រប់គ្រងបំណុលក្រៅប្រទេសដោយៈ (i) ពង្រឹង នីតិក្របខ័ណ្ឌ និង ភាពចាំបាច់នៃស្ថាប័ន និង សំរបសំរួលអង្គការចាត់តាំង និងនីតិវិធី រាយការណ៍ ចំពោះការងារគ្រប់គ្រងបំណុលក្រៅប្រទេស និងរបបរាយការណ៍ និង (ii) បង្កើតអង្គភាពគ្រប់គ្រងបំណុលសាធារណៈក្រោមឱវាទនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

(ឃ) ពង្រឹង សមត្ថភាពស្ថាប័ន អ្នកខ្ចីសំរាប់កែ ទំរង់ផ្នែកគ្រប់គ្រងមុខងារសាធារណៈ ដោយ តាក់តែងយុទ្ធសាស្ត្រត្រៀមបំរុង និង បង្កើតជំរើសដែលទាក់ទងជាមួយដើម្បីរៀបចំឡើងវិញ នូវមុខងារសាធារណៈរបស់អ្នកខ្ចី និង បង្កើនប្រសិទ្ធភាពរបស់វាទាំងនៅក្នុង សហគ្រាសសាធារណៈទៀតផង ។

២–សាងសង់ និងបំពាក់បរិក្ខារមជ្ឈមណ្ឌលបណ្ដុះបណ្ដាល វិក្រឹតការ និងសុក្រឹតការជំនាញបច្ចេកទេស ចំនួនប្រហែលប្រាំមួយរយអ្នក (៦០០) ក្នុងមួយឆ្នាំខាងការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

៣–ផ្គត់ផ្គង់ ម៉ាស៊ីនកុំព្យូទ័រ និងសេវា យានយន្ត និងបរិក្ខារស្វ័យប្រវត្តិ ចំពោះសំភារៈ និងមូលដ្ឋានប្រមូលទិន្នន័យ សមស្របទៅនឹងសកម្មភាពសំរាប់កថាខ័ណ្ឌ ១ខាងលើ ។

**ផ្នែក ខៈ ជំនួយការ បច្ចេកទេសគតិយុត្តដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន**

១–អនុវត្តការសិក្សានីតិព្យាករណ៍ដើម្បីកំណត់ (ក) វិធីសាស្ត្រ និង បទបញ្ញត្តិអភិវឌ្ឍន៍បច្ចុប្បន្ន នៃច្បាប់និងបទបញ្ញាសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង(ខ)កំរិតសមត្ថភាពនៃច្បាប់ និង បទបញ្ញា

ផ្សេងៗ នៃ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុព្រមទាំងបទបញ្ញាទាំងឡាយដែលកំពុងអនុវត្តជាធរមាន ទៅទីកដីរបស់អ្នកខ្ចី ។

២–ធ្វើការប៉ាន់ស្មាន តំរូវការបណ្តុះបណ្តាល ពេញលក្ខណៈច្បាប់ ដើម្បីកំណត់អោយបាននូវតំរូវការស្របច្បាប់ ជាអាទិភាពរបស់អ្នកខ្ចីព្រមទាំងធ្វើសំណូមពរកម្មវិធី សមស្របចាំបាច់ដល់តំរូវការទាំងនេះ ។

៣–ផ្អែកតាមការរកឃើញ និងអនុសាស្រ្តនៃការសិក្សាស្រាវជ្រាវ និងប៉ាន់ស្មានទៅក្នុងកឋាខ័ណ្ឌ១ និង ២ ដូចបានចែងខាងលើ និងស្ថានភាពផ្លូវការរបស់អ្នកខ្ចីស្តីពីច្បាប់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាទិភាពដោយអនុលោមតាមផ្នែក ៣,០៥ (ខ)នៃកិច្ចព្រមព្រៀងនេះត្រូវរៀបចំ និង អនុវត្តកម្មវិធី ផែនការម្ចាស់ការ ដើម្បីព្រាងនិងត្រួតពិនិត្យច្បាប់ និងបទបញ្ញាជាអាទិភាព នៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង(ខ)រៀបចំបើក សិក្ខាសាលាបណ្តុះបណ្តាលលក្ខណៈច្បាប់សំរាប់ ចៅក្រម,យុត្តិវិទូ មន្រ្តីរាជការ ព្រមទាំងវិជ្ជាជីវៈផ្សេងៗ ទៀតរបស់អ្នកខ្ចី។

៤–បង្កើតប្រព័ន្ធស្វ័យប្រវត្តិ ដើម្បីបោះពុម្ពលើមូលដ្ឋានទៀងទាត់ (ក)រាជកិច្ចរបស់អ្នកខ្ចីជាភាសាខ្មែរបារាំង និងអង់គ្លេស (ខ)សេចក្តីសំរេចរបស់តុលាការកំពូលរបស់អ្នកខ្ចី និងសេចក្តីទាំងឡាយស្តីពីលិទ្ធិ និងនីតិសាស្រ្ត និង (គ)សៀវភៅតម្កល់ម៉ាកសញ្ញាដោយ ពណ

៥–ផ្តត់ផ្គង់ម៉ាស៊ីនកុំព្យូទ័រកម្មវិធី បរិក្ខារស្វ័យប្រវត្តិ សំភារៈមូលដ្ឋានប្រមូលទិន្និន័យសមស្របតាមសកម្មភាព កឋាខ័ណ្ឌ ១,២,៣ និង ៤ ដូចបានចែងខាងលើ ។

**ផ្នែក គៈ ពង្រឹងបណ្តុះបណ្តាលសិក្សាស្រាវជ្រាវ និងស្ថាប័ន**

១–អនុវត្តកម្មវិធីបណ្តុះបណ្តាល (ទាំងក្នុងស្រុកនិងក្រៅស្រុក) ការងារប្រតិបត្តិ សមស្របតាមសកម្មភាពដែលបានចែងក្នុងផ្នែក ក និង ខ ខាងលើ ។

២–ផ្តត់ផ្គង់សេវានីតិប្រឹក្សាដល់ កច,គណ, ពណ,យធ និង គអក

៣–អនុវត្ត (i) សិក្សាស្រាវជ្រាវលើកិច្ចអភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុ របស់អ្នកខ្ចី និង (ii) សិតសំរាំងការសិក្សា គោលនយោបាយផ្អែកតាមវិស័យសេដ្ឋកិច្ចរបស់អ្នកខ្ចី ដូចៈ វាក្យខ័ណ្ឌៈ កសិកម្ម ពាណិជ្ជកម្ម អប់រំ ថាមពល បរិដ្ឋាន សុខាភិបាល ឧស្សាហកម្ម ស្ថិតិ និងភាពដែលអាចធ្វើទៅ បានតាមកម្មវិធីអាស្សាណ្ហ នៃការផ្ទេរបេឡាទៅខេត្តក្រុង ។

៤–ផ្តត់ផ្គង់ជំនួយសំភារៈបច្ចេកទេស និងបណ្តុះបណ្តាលដូច អគគ ក្នុងកិច្ចអនុវត្តន៍ការងារគ្រប់គ្រងគំរោងការ សំរបសំរួល អនុវត្ត ត្រួតពិនិត្យ និងការទទួលខុសត្រូវខាងផ្នែកដេញថ្លៃ ។

៥–ផ្តត់ផ្គង់សំភារៈបរិក្ខាររួមមាន ម៉ាស៊ីនកុំព្យូទ័រ សំភារៈការិយាល័យ បណ្តុះបណ្តាលសមស្រប

តាមសកម្មភាពដែលបាន កំណត់នៅកថាខណ្ឌ ១.២.៣ និង ៤ខាងលើ ។

## ឧបសម្ព័ន្ធ នៃកម្មវិធី ២

ភ្នាក់ងារស្ថាប័នរដ្ឋ របស់អ្នកខ្ចី ដែលបានរាយនាមដូចខាង ទទួលខុសត្រូវក្នុងការជួយជ្រោមជ្រែង រួមចំណែកជាមួយក្រសួងសេដ្ឋកិច្ច និង អនុវត្តន៍គំរោងការ ។

| **ផ្នែកនៃគំរោងការ** | **ស្ថាប័ន / ភ្នាក់ងារ** |
|---|---|
| ផ្នែក ក(១)(ក) | សហវ |
| ផ្នែក ក(១)(ខ) | សហវ/កអក |
| ផ្នែក ក(១)(គ) | សហវ |
| ផ្នែក ក(១)(ឃ) | គណា / កអក |
| ផ្នែក ក(២) | សហវ |
| ផ្នែក ក(៣) | អគត |
| ផ្នែក ខ(១) | កអក/កប/ពណា/យធ |
| ផ្នែក ខ(២) | កអក/កប/គណា/យធ |
| ផ្នែក ខ(៣) | គណា/កប/យធ |
| ផ្នែក ខ(៤) | គណា/ពណា/យធ |
| ផ្នែក ខ(៥) | អគត |
| ផ្នែក គ(១) | អគត |
| ផ្នែក គ(២) | កប/គណា/ពណា/យធ |
| ផ្នែក គ(៣) | សហវ |
| ផ្នែក គ(៤) | អគត |
| ផ្នែក គ(៥) | អគត |

## កម្មវិធី ៣

## កិច្ចការដេញថ្លៃ និងអ្នកពិគ្រោះ

### ផ្នែក I: ដេញថ្លៃទំនិញ និងពលកម្ម

### ភាគ ក : ដេញថ្លៃតាមការប្រកួតប្រជែងអន្តរជាតិ

១–លើកលែងករណីដែលបានចែងក្នុងភាគ គ ទំនិញទាំងឡាយត្រូវបានផ្គត់ផ្គង់ក្រោមកិច្ចសន្យា ត្រឹមត្រូវតាមកម្មវិធីដែលបានចែងនៅក្នុងផ្នែក I និង II នៃការណែនាំដេញថ្លៃ ខ្ចីប្រាក់ «របស់ធនាគារអន្តរជាតិដើម្បីទីតាំងសម្បទា និងអភិវឌ្ឍន៍ » និង ឥណទានរបស់សមាគម អភិវឌ្ឍន៍អន្តរជាតិ (Guidelines for Procurement under IBRD and IDA Credits) ដែលបានបោះផ្សាយ ដោយធនាគារនៅខែ ឧសភា ឆ្នាំ ១៩៩២ «ការណែនាំ» ព្រមទាំងសម ស្របតាមនីតិវិធីលំអិតដូចតទៅ :

(ក) កាលណាកិច្ចសន្យាមានការយឺតយ៉ាវ ហួសរយៈពេលសុពលភាព នៃការដេញថ្លៃដែល បានកំណត់ពីដើមទីនោះរយៈពេលនេះអាចត្រូវបានពន្យារមួយដងសមស្រប និង អនុលោមតាមបទបញ្ញត្តិ កថាខ័ណ្ឌ ២,៥៩ នៃ «ការណែនាំ» នូវចំនួនពេលអប្បបរមា មួយសំរាប់ បំពេញការវាយតំលៃ ប្រកាសយល់ព្រមជាចាំបាច់ ហើយនិងចុះកិច្ចសន្យា ។ រយៈពេលសុពលភាពនៃការដេញថ្លៃ អាចត្រូវបានពន្យារពេលជាលើកទី២ ក្នុងករណី ដែលឯកសារដេញថ្លៃ ឬ ការទាមទារពន្យារពេលផ្តល់នូវការកែតំរូវមួយយ៉ាងសមស្រប អំពីថ្លៃផ្គត់ផ្គង់ ដើម្បីឆ្លុះបញ្ចាំង ការប្រែប្រួលនៃបរិយាទានលទ្ធកម្មរបស់កិច្ចសន្យាក្នុងរយៈ ពេល នៃការពន្យារពេល ។ ការបង្កើនថ្លៃផ្គត់ផ្គង់ កត់ត្រាចូលក្នុងគណនីនៅដំណាក់ វាយតំលៃឡើយ ។ ចំពោះកិច្ចសន្យានីមួយៗដែលបានឆ្លងយោបល់សមាគមត្រួត ពិនិត្យជាមុនសមស្របតាមបញ្ញត្តិ ភាគ ឃ ១ នៃផ្នែកនេះ ការយល់ព្រមជាមុនរបស់ សមាគមទាមទារ: (i) ការពន្យារពេល លើកទី១ នៃរយៈពេលសុពលភាពនៃការដេញថ្លៃ បើរយៈពេលពន្យារនេះហួសចំនួន ៦០ ថ្ងៃ និង(ii) ការពន្យាពេលលើកក្រោយ នៃរយៈពេលសុពលភាពនៃការដេញថ្លៃ ។

(ខ) ក្នុងការដេញថ្លៃទំនិញទៅតាមភាគ ក នេះអ្នកខ្ចីត្រូវប្រើប្រាស់បញ្ជីគំរូនៃឯកសារដេញថ្លៃ ដែលប្រកាសអោយប្រើដោយធនាគារ អ្នកខ្ចីអាចប្រើប្រាស់ឯកសារដេញថ្លៃផ្សេងៗ ទៀត ដែល អន្តរជាតិ ទទួលស្គាល់ ហើយសមាគមក៏បានយល់ព្រមផងដែរ ។

### ភាគ ខ : ចំណូលចិត្តទៅលើផលិតករក្នុងស្រុក

១-ក្នុងការដេញថ្លៃ ទំនិញតាមនីតិវិធីដែលបានអធិប្បាយក្នុងភាគ ក១ ខាងលើ ទំនិញកម្មន្តសាល ក្នុងទឹកដីរបស់អ្នកខ្ចី អាចទទួលយល់ព្រមបាន ក្នុងកំរិតចំណូលចិត្តមួយ សមស្របត្រឹមត្រូវតាម បទបញ្ញត្តិកថាខ័ណ្ឌ ២.៥៥ និង ២.៥៦ និងកថាខ័ណ្ឌពី ១ដល់៤ នៃឧបសម្ព័ន្ធ ២នៃ «ការណែនាំ» ។

**ភាគ គ: នីតិវិធីដេញថ្លៃផ្សេងៗទៀត**

**១—ដេញថ្លៃតាមការប្រជែងក្នុងស្រុក** :កិច្ចសន្យាសំរាប់ទំនិញ «រួមទាំងយានយន្ត » និងពលកម្ម ដែលមានតំលៃសមមូល តិចជាងពីររយពាន់ដុល្លារ (២០០.០០០) ក៏ប៉ុន្តែ ច្រើនជាង ហាសិប ពាន់ដុល្លារ (៥០.០០០) ក្នុងកិច្ចសន្យាមួយរហូតដល់ចំនួនទឹកប្រាក់សរុប សមមូលនឹងប្រាំបួន រយពាន់ ដុល្លារ (៩០០.០០០) អាចត្រូវបានផ្គត់ផ្គង់ដោយកិច្ចសន្យា ផ្អែកតាមប្រកាសដេញថ្លៃ ប្រជែងគ្នាក្នុង ស្រុកទៅតាមនីតិវិធីសមស្របរបស់សមាគម ។

**២—ដេញថ្លៃតាមការពិគ្រោះ** : កិច្ចសន្យាទំនិញ «រួមទាំងយានយន្ត » និងពលកម្មដែលមាន តំលៃសមមូលស្មើនឹង ឬ តិចជាងហាសិបពាន់ដុល្លារ (៥០.០០០) ក្នុងមួយកិច្ចសន្យារហូត ដល់ចំនួនទឹកប្រាក់សរុបសមមូលនឹងប្រាំមួយរយពាន់ដុល្លារ (៦០០.០០០) អាចត្រូវចុះកិច្ច សន្យាផ្អែកតាមការប្រៀបធៀបបញ្ជីថ្លៃយ៉ាងហោចណាស់មកពីអ្នកផ្គត់ផ្គង់បី (៣) ដែលអាចជ្រើសតាំងបានក្រោម «ការណែនាំ» សមស្របតាមនីតិវិធីដែលសមាគមអាច ទទួលយល់ព្រមបាន ។

**ភាគ ឃ : សេចក្តីសំរេចនៃការដេញថ្លៃ ពិនិត្យដោយសមាគម**

១-ពិនិត្យលើការប្រកាសចូលរួមដេញថ្លៃ បញ្ញត្តិ និង កិច្ចសន្យាចុងក្រោយ :

(ក) ចំពោះកិច្ចសន្យានីមួយៗដែលត្រូវបានផ្គត់ផ្គង់តាមបទបញ្ញត្តិនៃភាគ ក-១ ខាងលើនិង ចំពោះកិច្ចសន្យាពីរដំបូង ដែលត្រូវបានផ្គត់ផ្គង់តាមបទបញ្ញត្តិ នៃភាគ គ-១និង គ-២ ខាងលើនីតិវិធី ដែលចែងក្នុងកថាខ័ណ្ឌ២ និង ៤ ឧបសម្ព័ន្ធ១ នៃការណែនាំ ត្រូវបាន អនុវត្ត ។ ក្នុងករណីដែលការទូ ទាត់កិច្ចសន្យាចេញពីគណនីពិសេស នីតិវិធីទាំងនេះត្រូវ បានផ្លាស់ប្តូរដើម្បីធានាថា ឯកសារចម្លងត្រឹមត្រូវចំនួនពីរច្បាប់នៃកិច្ចសន្យា ដែលត្រូវ ផ្តល់អោយសមាគមសមស្របតាមកថាខ័ណ្ឌ២ (ឃ) ដែល បាននិយាយខាងលើត្រូវផ្តល់ ជូនសមាគមមុននឹងធ្វើការទូទាត់លើកទី១ ពីគណនីពិសេសក្នុងការគោរព ទៅតាមកិច្ច សន្យានេះ ។

(ខ) ចំពោះកិច្ចសន្យានីមួយៗដែលមិនបានគ្រប់គ្រងដោយកថាខ័ណ្ឌ នីតិវិធីដែលបាន

ចែងនៅក្នុងកថាខ័ណ្ឌ៣ និង៤នៃឧបសម្ព័ន្ធ១ នៃ «ការណែនាំ» ត្រូវបានអនុវត្ត ។ ក្នុងករណីដែលការទូទាត់កិច្ចសន្យានេះធ្វើឡើងនៅក្រៅគណនីពិសេសនីតិវិធីទាំងនេះត្រូវបានផ្លាស់ ប្តូរដើម្បីជានាថាឯកសារចម្លង ត្រឹមត្រូវចំនួនពីរច្បាប់នៃកិច្ចសន្យាព្រមទាំងពត៌មានផ្សេងៗ ទៀតដែលត្រូវផ្តល់ជូនសមាគមសមស្រប តាមកថាខ័ណ្ឌ៣ ដែលបាននិយាយខាងលើ ត្រូវផ្តល់ជូនសមាគមទុកជាភស្តុតាងសមស្របតាមកថាខ័ណ្ឌ៤ នៃកម្មវិធី៤ របស់កិច្ចព្រមព្រៀងនេះ ។

(គ) បទបញ្ញត្តិនៃវាក្យខ័ណ្ឌ (ខ) ខាងលើមិនត្រូវបានអនុវត្តចំពោះកិច្ចសន្យាទាំងឡាយណាដែលការដកប្រាក់ពីគណនីឥណទាន គឺត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃស្ថានភាពចំណាយ ។

២–តួលេខចំនួនដប់ប្រាំភាគរយ (១៥%) ត្រូវបានកំណត់នៅទីនេះ ជាគោលបំណងនៃកថាខ័ណ្ឌ ៤ នៃឧបសម្ព័ន្ធ១ នៃការណែនាំ ។

**ផ្នែក II—ការប្រើប្រាស់អ្នកពិគ្រោះ**

១–ដើម្បីជួយជ្រោមជ្រែងអ្នកខ្ចីក្នុងកិច្ចអនុវត្តគំរោងការ អ្នកខ្ចីនឹងប្រើប្រាស់អ្នកពិគ្រោះដែលមានលក្ខណៈសម្បត្តិ បទពិសោធន៍ កាលកំណត់និងល័ក្ខខ័ណ្ឌនៃការងារត្រូវបំពេញទៅតាមសមាគម ។ អ្នកពិគ្រោះទាំងនេះត្រូវបានជ្រើសរើសសមស្របទៅតាមគោលការណ៍និងនីតិវិធីរបស់សមាគម ។ ដោយផ្អែកតាមការណែនាំនៃការប្រើប្រាស់អ្នកពិគ្រោះរបស់អ្នកខ្ចីនិងធនាគារពិភពលោកដែលជាភ្នាក់ងារអនុវត្តបោះពុម្ពផ្សាយដោយធនាគារ នៅខែសីហា ១៩៨១ (ការណែនាំអ្នកពិគ្រោះ) ។

២–ចំពោះកិច្ចការជ្រើសតាំងដ៏សាំញាំនេះ អ្នកខ្ចីជ្រើសរើសអ្នកពិគ្រោះទាំងនេះដោយធ្វើកិច្ចសន្យាតាមគំរូរបស់ធនាគារដែលអាចផ្លាស់ប្តូរបានតាមការព្រមព្រៀងជាមួយសមាគម ។ ក្នុងករណី ដែលគ្មានឯកសារកិច្ចសន្យាជាគំរូចេញដោយធនាគារនោះអ្នកខ្ចីអាចប្រើប្រាស់លិខិតគំរូផ្សេងទៀត ដោយមានការយល់ព្រមពីសមាគមផង ។

៣–ដោយបដិបញ្ញត្តិចំពោះកថាខ័ណ្ឌ១ នៃផ្នែកនេះ បទបញ្ញត្តិនៃការណែនាំអ្នកពិគ្រោះដែលតម្រូវអោយមានការត្រួតពិនិត្យពីសមាគម រឺយល់ព្រមថវិកា បញ្ជីរាយនាមរយៈពេលខ្ចីសំរាំងនីតិវិធី លិខិតប្រកាសចូលរួម សំណើរបាយការណ៍វាយតំលៃព្រមទាំងកិច្ចសន្យាធានាមិនត្រូវបាន អនុវត្ត ចំពោះ : (ក) កិច្ចសន្យាជាមួយក្រុមហ៊ុនពិគ្រោះដែលមានតំលៃសមមូលតិចជាងមួយរយពាន់ដុល្លារ (១០០.០០០) ក្នុងមួយកិច្ចសន្យា រឺ (ខ) កិច្ចសន្យាជាមួយបុគ្គលពិគ្រោះដែល (ខ) តំលៃសមមូលតិច ជាងហាសិបពាន់ (៥០.០០០) ក្នុងមួយកិច្ចសន្យា ។

យ៉ាងណាក៏ដោយការលើកលែងនេះ ចំពោះការពិនិត្យជាមុនរបស់សមាគមមិនត្រូវបានអនុវត្ត : (i) លក្ខខ័ណ្ឌ បង្វែកនៃកិច្ចសន្យាទាំងនេះ (ii) ប្រភពជ្រើសរើសចេញពីក្រុមហ៊ុនតែមួយ (iii) កិច្ចការមាន លក្ខណៈកំណត់ សមហេតុសមផលពីសមាគម (iv) វិសោធនកម្មចំពោះកិច្ចសន្យាដែលធ្វើជាមួយក្រុមហ៊ុនពិគ្រោះ ដែលតំលៃកិច្ចសន្យាសមមូល ឬច្រើនជាងមួយរយពាន់ដុល្លារ (១០០.០០០) រឺ (v) វិសោធនកម្មចំពោះកិច្ចសន្យាជ្រើសរើសបុគ្គលពិគ្រោះ ដែលមានតំលៃកិច្ចសន្យាសមមូល រឺច្រើនជាងហាសិបពាន់ដុល្លារ (៥០.០០០)។

## កម្មវិធី៤

## គណនីពិសេស

**១-គោលបំណងនៃកម្មវិធីនេះ**

(ក) ពាក្យ « ប្រភេទជ្រើសតាំង »មានន័យថាប្រភេទ (១),(២),(៣),(៤) និង (៥) ដែលបានថែងក្នុងតារាងកថាខ័ណ្ឌ១ នៃកម្មវិធី១ ក្នុងកិច្ចព្រមព្រៀងនេះ ។

(ខ) ពាក្យ «ចំណាយជ្រើសតាំង» មានន័យថាចំណាយទៅតាមតម្លៃទំនិញ និងសេវាក័សមស្រប របស់គំរោងការ ហើយ ត្រូវបានហិរញ្ញសម្បទានពីចំនួនទឹកប្រាក់នៃគណនីពិសេសផ្តល់អោយ «ប្រភេទជ្រើសតាំង» ជាបណ្តើរៗសមស្របតាមបទបញ្ញត្តិកម្មវិធី១ នៃកិច្ចព្រមព្រៀងនេះ និង

(គ) ពាក្យ «ប្រាក់វិភាគយល់ព្រម» មានន័យថា ចំនួនប្រាក់សមមូលមួយលានដុល្លារ (១,០០០,០០០) ត្រូវបានដកចេញពី គណនីឥណទាន ហើយត្រូវបានតំកល់ក្នុងគណនីពិសេស អនុលោមតាមកថាខ័ណ្ឌ ៣(ក) នៃ កម្មវិធីនេះ ។ ក៏ប៉ុន្តែបើពុំនោះទេ លុះត្រាតែសមាគមឯកភាព ប្រាក់វិភាគយល់ព្រមត្រូវបានកំរិតសមមូល បីរយពាន់ដុល្លារ (៣០០,០០០) រហូតដល់ទឹកប្រាក់សរុប ដែលត្រូវដកពីគណនីឥណទាន បូកចំនួនប្រាក់សរុបដែលកំពុងស្ថិតនៅ ជាសន្យាពិសេសដោយធនាគារ អនុលោមតាមផ្នែក ៥,០២ នៃ «លក្ខខ័ណ្ឌទូទៅ » ស្មើនិងឬលើសចំនួនប្រាំពាន់ដុល្លារ (៥,០០០,០០០) ។

២-ការទូទាត់ពីគណនីពិសេស ធ្វើទៅបានចំពោះចំណាយ ជ្រើសតាំងតែប៉ុណ្ណោះ ស្របតាមបទបញ្ញត្តិនៃកម្មវិធីនេះ ។

៣-ក្រោយពេលដែលសមាគម បានទទួលសក្ខីភាព ជាទីពេញចិត្តហើយនោះ គណនីពិសេសត្រូវបានបើកនៅពេលមួយជាកំណត់ ការដកប្រាក់ជាវិភាជន៍យល់ព្រម [illegible] ៈដកប្រាក់

លើក ក្រោយៗ ទៀតដើម្បីបំពេញឡើងវិញអោយគណនីពិសេសនឹងត្រូវប្រព្រឹត្តិទៅដូចតទៅ:

(ក) ដើម្បីដកប្រាក់ វិភាជន៍យល់ព្រម អ្នកខ្ចី ត្រូវផ្តល់អោយសមាគម នូវពាក្យសុំមួយ ឬមួយចំនួនសំរាប់តម្កល់ក្នុងគណនីពិសេស ជាទឹកប្រាក់មួយឬទឹកប្រាក់ទាំងឡាយដែលកំណត់ដោយ សមាគមស្មើនូទាត់ចំពោះចំណាយជ្រើសតាំង ក្នុងរយៈពេលបួនខែ ទៅតាម ការបរិច្ឆេទនៃពាក្យស្នើសុំនិមួយៗដែលមានទឹកប្រាក់ មិនអោយលើសចំនួនទឹកប្រាក់សរុប នៃប្រាក់វិភាជន៍យល់ព្រម ។ ផ្អែកលើ មូលដ្ឋាន ស្នើសុំមួយ ឬមួយចំនួននេះ សមាគម នឹងដកប្រាក់ពីគណនីឥណទាន ក្នុងនាមអោយអ្នកខ្ចី ហើយបង្វែរចូលគណនីពិសេសនូវចំនួនទឹកប្រាក់ទាំងនេះ ដែលសមាគមបានកំណត់ដូចដែលបានស្នើសុំ ។

(ខ) (i) ដើម្បីបំពេញគណនីពិសេសឡើងវិញ អ្នកខ្ចីត្រូវផ្តល់ ជូនសមាគមនូវពាក្យស្នើសុំសំរាប់បញ្ចូលក្នុងគណនីពិសេសនៅចន្លោះពេលដែលសមាគមនឹងបញ្ជាក់ជូន ។ (ii) មុន ឬ នៅពេលដាក់ ពាក្យស្នើសុំ អ្នកខ្ចីត្រូវផ្តល់ ជូនសមាគមនូវឯកសារ និង សក្ខីប័ត្រផ្សេងៗ ទៀតសមស្របកថាខ័ណ្ឌ៤ នៃ កម្មវិធីនេះដើម្បីស្នើសុំទូទាត់អ្វីមួយ ឬ ច្រើនមុខក្នុងគោល បំណងស្នើសុំបំពេញឡើងវិញ ។ ផ្អែកលើ មូលដ្ឋាននៃសំណើសុំនីមួយៗនេះ ក្នុងនាម អោយអ្នកខ្ចី សមាគមធ្វើការដកប្រាក់នេះ ដូចដែលអ្នកខ្ចីបានស្នើសុំនិងដូចបានបញ្ជាក់ បង្ហាញនៅក្នុងឯកសារ និងសក្ខីប័ត្រផ្សេងៗបានទូទាត់រួចមកហើយពីគណនីពិសេសចំពោះចំណាយជ្រើសតាំងទាំងនោះ ។ គ្រប់ប្រាក់បញ្ញើទាំងនេះ ត្រូវបានសមាគមដកចេញពីគណនីឥណទានក្រោមប្រភេទជ្រើសតាំងនានា និងបិតនៅក្នុងចំនួនទឹកប្រាក់ត្រូវគ្នាដូចដែលបានបញ្ជាក់នៅក្នុងឯកសារ និងសក្ខីប័ត្រផ្សេងៗ ដែលបានផ្ញើជូន ។

៤–ចំពោះការទូទាត់នីមួយៗ ដែលអ្នកខ្ចី បានធ្វើឡើងពីគណនីពិសេស នៅពេលនោះ សមាគមទាមទារអោយអ្នកខ្ចី ផ្តល់ជូននូវឯកសារ និង សក្ខីប័ត្រផ្សេងៗទាំងនេះដើម្បីបង្ហាញប្រាប់ថាការទូទាត់នេះបានធ្វើឡើងត្រឹម ត្រូវជាចំខាតអោយមុខចំណាយជ្រើសតាំងប៉ុណ្ណោះ ។

៥–ដោយបដិបញ្ញត្តិ ចំពោះកថាខ័ណ្ឌ៣ នៃកម្មវិធីនេះ សមាគមមិនត្រូវការទាមទារអោយធ្វើការតំកល់ប្រាក់ជាលំអិតក្នុងគណនីពិសេសទេ :

(ក)នៅពេលមួយ បើសមាគម បានកំណត់ឃើញថា ការដកប្រាក់ជាលំអិត ទាំងអស់ត្រូវបានធ្វើឡើងដោយអ្នកខ្ចី ទៅតាមបែបបទផ្ទាល់ពីគណនីឥណទាន សមស្របតាមបទបញ្ញត្តិនៃមាត្រារបស់ «ល័ក្ខខ័ណ្ឌទូទៅ » និងតាមកថាខ័ណ្ឌផ្នែក ២,០២ នៃកិច្ចព្រមព្រៀងនេះ ។

(ខ) បើអ្នកខ្ចី មានការខ្វះខាតក្នុងការ ផ្តល់ជូនសមាគម ក្នុងរយៈពេលដែលបានកំណត់ ក្នុងផ្នែក ៤ ,០១ នៃកិច្ច ព្រមព្រៀងនេះរបាយការណ៍ត្រួតពិនិត្យគណនីត្រូវផ្តល់ជូនសមាគមអនុលោមតាមផ្នែកដែលនិយាយនេះ ស្តីពីការត្រួតពិនិត្យកិច្ចបញ្ជីកា និងគណនីទាំងឡាយចំពោះគណនីពិសេស។

(គ) នៅពេលណាមួយ បើសមាគមបានប្រកាសដល់អ្នកខ្ចី នូវគោលបំណងរបស់គេសូមបញ្ឈប់សិទ្ធិរបស់អ្នកខ្ចី ស្នើការដកប្រាក់ទាំងស្រុងឬ មួយចំណែកណានោះ ចេញពីគណនីឥណទាន ដោយអនុលោមតាមបទបញ្ញត្តិនៃផ្នែក ៦,០២ របស់ «ល័ក្ខខ័ណ្ឌ » ឬ

(ឃ)នៅពេលដែលចំនួនសរុបឥណទាន មិនបានដកពីប្រភេទជ្រើសតាំងដក (–) ចំនួនប្រាក់រង់ចាំទូទាត់នៃការសន្យាពិសេស ដែលបានព្រមព្រៀងដោយសមាគមសមស្របតាមផ្នែក ៥,០២ នៃល័ក្ខខ័ណ្ឌទូទៅសំរាប់គំរោងការគិតជាសមមូលស្មើ នឹងពីរដងនៃ «ចំនួនប្រាក់ដែលបានអនុញ្ញាត » ។ ក្រោយពីនេះ ការដកប្រាក់ពីគណនីឥណទានដែលជាចំនួនឥណទាននៅសល់មិនបានដកសំរាប់ប្រភេទជ្រើសតាំងអាចបន្តតាម នីតិវិធីដែលសមាគម នឹងបញ្ជាក់តាមប្រកាសជូនអ្នកខ្ចី។ ការដកប្រាក់តទៅទៀត អាចស្នើទៅបានក្រោយពីសមាគមបានយល់ឃើញថា ចំនួនប្រាក់នៅសល់ក្នុងគណនីពិសេសពីអំណើះតទៅ នៃការប្រកាស នេះត្រូវបានប្រើប្រាស់ក្នុងការទូទាត់សំរាប់ចំណាយជ្រើសតាំង ។

៦–(ក) បើសមាគមបានកំណត់វិញថាខ្វះការទូទាត់ចេញពី គណនីពិសេស (i) បានធ្វើឡើងសំរាប់ចំណាយណាមួយ ឬក្នុងចំនួនប្រាក់មួយចំនួន នៅក្រៅការជ្រើសតាំងដោយអនុលោម តាមកឋាខ័ណ្ឌ២ នៃកម្មវិធីនេះ ។ ឬ (ii) ពុំបានធ្វើយុត្តិកម្មជាសក្ខីប័ត្រត្រឹមត្រូវផ្តល់ជូនសមាគមនោះផ្នែកតាមប្រកាសរបស់សមាគម អ្នកខ្ចី ត្រូវប្រុងប្រៀប (ក) ផ្តល់សក្ខីប័ត្រជាលំអិតទាំងនេះនៅពេលសមាគមត្រូវការ ឬ (ខ) តម្កល់ទឹកប្រាក់អោយស្មើនឹងចំនួន ប្រាក់ទូទាត់នេះ ឬស្មើនិងចំណែកទឹកប្រាក់ ដែលនៅក្រៅការជ្រើសតាំង ឬ ពុំបានធ្វើយុត្តិកម្មចូលក្នុងគណនីពិសេសវិញ (ឬត្រូវសងជូនសមាគម វិញក្នុងករណីសមាគម ត្រូវការ) ។ លើកលែងសមាគមយល់ព្រមប្រាក់បញ្ញើជាថ្មីរបស់សមាគមចូលក្នុងគណនីពិសេសពុំអាចធ្វើទៅបានឡើយរហូតដល់អ្នកខ្ចី បានផ្តល់សក្ខីប័ត្រទាំងនេះឬបានតម្កល់ប្រាក់ ឬ បានសងប្រាក់រួចរាល់តាមករណីដែលអាចកើតមានឡើង ។

(ខ) នៅពេលណាមួយបើសមាគមបានកំណត់ឃើញថា ចំនួនប្រាក់ដែលកំពុងជំពាក់នៅក្នុងគណនីពិសេសមិនបានទាមទារ សំរាប់ការទូទាត់បន្តអោយចំណាយជ្រើសតាំងនោះ ផ្នែក

តាមប្រកាសរបស់សមាគម អ្នកខ្ចីត្រូវសងចំនួនប្រាក់ជំពាក់នេះអោយសមាគមជាបន្ទាន់ ។

(គ) ផ្នែកតាមប្រកាស ជូនសមាគម អ្នកខ្ចីត្រូវសងទាំងអស់ ឬចំណែកណាមួយនៃមូលនិធិប្រាក់បញ្ញើនៅក្នុងគណនីពិសេស ។

(ឃ) ការសងប្រាក់ជូនសមាគម ដែលធ្វើឡើងដោយអនុលោមតាមកថាខ័ណ្ឌ ៦ (ក) (ខ) និង (គ) នៃកម្មវិធីនេះត្រូវបានចុះឥណទានអោយ «គណនីឥណទាន » សំរាប់ការដកប្រាក់នៅពេលក្រោយឬសំរាប់ការលុបចោលផ្នែកតាមបទបញ្ញត្តិដ៏សមហេតុសមផលនៃកិច្ចព្រមព្រៀងនេះ រួមទាំងល័ក្ខខ័ណ្ឌទូទៅ » ផង ។

* * *

# កម្មវិធី ៥

## ផែនការអនុវត្តន៍គំរោង

| គោលដៅ<br>គំរោង | សកម្មភាព<br>គំរោងសំខាន់ៗ | កំណត់<br>ពេលវេលា | កម្មវិធីការងារ<br>វិធានការសំខាន់ៗ | កំណត់ពេលវេលា |
|---|---|---|---|---|
| <u>ឃ្លាំមើលចំណាយសាធារណៈ</u> | | | រៀបចំកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំសំរាប់បុគ្គលិកសមភាគី | ៣១ មីនា |
| «<u>ការគ្រប់គ្រងថវិកា និងរតនាគារ</u>» | <u>ជ្រើសរើស</u> : | | រៀបចំកម្មវិធី T&V សំរាប់សមភាគីបុគ្គលិកតាមក្រសួងនានា និងខេត្ត-ក្រុង | ៣១ មីនា |
| ពង្រឹង : | -ទីប្រឹក្សាហិរញ្ញវត្ថុសាធារណៈ (SPF) | មករា ១៩៩៥ | កាត់តែងសំរេចក្របខ័ណ្ឌស្ថាប័ន សំរាប់ត្រួតពិនិត្យចំណាយ | ៣១ ធ្នូ ១៩៩៦ |
| -សមត្ថភាពធ្វើគំរោងថវិកា | -ទីប្រឹក្សាថវិកា និង រតនាគារ (SBT) | មករា ១៩៩៥ | បង្កើតក្រុមដំបូង នៃមន្ត្រីអភិបាលហិរញ្ញវត្ថុ | ៣១ ធ្នូ ១៩៩៥ |
| -ត្រួតពិនិត្យចំណាយ | -អ្នកបច្ចេកទេសថវិកា ៥ រូប (BTS) | មករា-មិថុនា ១៩៩៥ | រៀបចំសន្និបាតបូកសរុបថវិកាប្រចាំឆ្នាំ | ៣០ កញ្ញា |
| -គ្រប់គ្រងសាច់ប្រាក់រតនាគារ | -ជំនាញគណនេយ្យសាធារណៈរតនាគារ | មីនា ១៩៩៥ | កាត់តែងសំរេចប្រព័ន្ធសំរាប់គ្រោងចំណូល និងចំណាយប្រចាំខែ | ៣១ ធ្នូ ១៩៩៥ |
| | <u>ផ្គត់ផ្គង់</u> : | | កាត់តែងសំរេចវិធាន និងនីតិវិធីសំរាប់ប្រមូលចំណូល និងកិច្ចប្រតិបត្តិការចំណាយ | ៣១ ធ្នូ ១៩៩៥ |
| | -បរិក្ខារការិយាល័យ | ១៩៩៥-៩៥ | -រៀបចំឡើងវិញ នូវគណនីរតនាគារ នៅតាមតារាងកាលនាមថវិកាថ្មី | ៣១ ធ្នូ ១៩៩៥ |
| | | | -បង្កើតវិធានថ្មី សំរាប់គ្រប់គ្រងគណនីរតនាគារ | ៣១ ធ្នូ ១៩៩៥ |
| <u>ការគ្រប់គ្រងវិនិយោគសាធារណៈ</u> | <u>អង្គភាព PIP និង អភិវឌ្ឍន៍ប្រព័ន្ធ PIP</u> | | | |
| -ពង្រឹងការងារកម្មវិធីវិនិយោគសាធារណៈ | <u>ជ្រើសរើស-សំរាំង</u> | | -បង្កើតអង្គភាព PLB ចាត់តាំងបុគ្គលិក | ៣១ ធ្នូ ១៩៩៥ |
| -អភិវឌ្ឍន៍សនិទានកម្មថវិកាវិនិយោគសាធារណៈ | -ទីប្រឹក្សា PIB | មីនា ១៩៩៥ | រៀបចំកម្មវិធីបណ្តុះបណ្តាល សំរាប់បុគ្គលិកសមភាគី | ១៩៩៥-៩៦ |
| -ពង្រឹងអង្គភាពគំរោងតាមក្រសួងនានា | -ជំនាញការចាត់តាំង PIB | មីនា ១៩៩៥ | រៀបចំកម្មវិធី T&V សំរាប់បុគ្គលិកសមភាគី តាមក្រសួងនានា | ១៩៩៥-៩៧ |
| -ពង្រឹងសម្របសម្រួលជំនួយ | -វិស្វករប្រព័ន្ធកុំព្យូទ័រ CSE | មិថុនា ១៩៩៥ | បែងចែកប្រព័ន្ធពតិមានវិទ្យា និង បណ្តុះបណ្តាលបុគ្គលិកប្រើប្រាស់ និង ថែទាំ | មីនា ១៩៩៦ |
| -ពង្រឹងផែនការកម្មជាយុទ្ធសាស្ត្រ | -អ្នកផ្គត់ផ្គង់ប្រព័ន្ធ | វិច្ឆិកា ១៩៩៥ | CSE សំរាប់គ្រប់គ្រង បែងចែកប្រព័ន្ធកុំព្យូទ័រ និង បណ្តុះបណ្តាល | មករា-មីនា ៩៦ |
| -អភិវឌ្ឍន៍សមត្ថភាពវិភាគម៉ាក្រូ | <u>ផ្គត់ផ្គង់</u> : | | បែងចែកសំភារៈបរិក្ខារការិយាល័យ | មេសា - ធ្នូ ១៩៩៥ |
| | -បរិក្ខារការិយាល័យ | ១៩៩៥-៩៦ | | |
| | <u>អង្គភាពគំរោងការតាមក្រសួងនានា</u> | | | |
| | <u>ជ្រើសរើស</u> : | | អភិវឌ្ឍន៍នីតិវិធី សំរាប់ត្រួតពិនិត្យតាមដានគំរោង | ៣០ មិថុនា ១៩៩៦ |
| | -ឯកទេសគ្រប់គ្រងគំរោង | មករា ១៩៩៦ | រៀបចំ ចងក្រងអត្ថបទសៀវភៅ | ៣១ ធ្នូ ១៩៩៦ |
| | -ឯកទេសសនិទានកម្ម កម្មវិធី | មករា ១៩៩៦ | បែងចែកប្រព័ន្ធកុំព្យូទ័រ ផ្សារភ្ជាប់ប្រព័ន្ធ PIB នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១៩៩៦-៩៧ |
| | -គណនេយ្យករ គំរោងការ | មករា ១៩៩៦ | បណ្តុះបណ្តាលបុគ្គលិក ប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ | មិថុនា ១៩៩៦ |
| | -គណនេយ្យករទូទៅ-ស្នងការគណនី | មករា ១៩៩៦ | | |
| | -ឯកទេសចាត់តាំង ០២ រូប | | | |

# កម្មវិធី ៥ «គ»

## ផែនការអនុវត្តគំរោង

| | | | | |
|---|---|---|---|---|
| | ផែនការកម្មជាយុទ្ធសាស្ត្រ និងសម្របសម្រួលជំនួយ | | | |
| | ជ្រើសរើស | | | |
| | -ទីប្រឹក្សាសម្របសម្រួលជំនួយ | មករា ១៩៩៥ | បង្កើតមូលនិធិសិក្សា | ៣១ មិថុនា ១៩៩៧ |
| | -អ្នកពិគ្រោះសំរាប់ទស្សនៈអនាគត | មិថុនា ១៩៩៥ | រៀបចំ និង អនុវត្តកម្មវិធីបណ្តុះបណ្តាល | ++ |
| | | | ផ្តល់យោបល់ «ទស្សនៈ» សិក្សាទៅរដ្ឋាភិបាល | ៣១ មីនា ១៩៩៦ |
| | -ជនជាតិកម្ពុជាមកពីក្រៅ | ១៩៩៥ | បែងចែកប្រព័ន្ធកុំព្យូទ័រ ភ្ជាប់ប្រព័ន្ធ PIB ទៅ គសហវ | មីនា ១៩៩៦ |
| | ផ្គត់ផ្គង់ : | | បែងចែកបរិក្ខារការិយាល័យ | ១៩៩៥/១៩៩៦ |
| | -បរិក្ខារការិយាល័យ | ១៩៩៥/៩៦ | | |
| | វិភាគម៉ាក្រូសេដ្ឋកិច្ច | | រៀបចំកម្មវិធីបណ្តុះបណ្តាល សំរាប់ព្យាករណ៍ វិភាគសេដ្ឋកិច្ច ។ល។ | ៣១ ធ្នូ ១៩៩៥ |
| | ជ្រើសរើស | | បង្កើតទិន្នន័យមូលដ្ឋាន | ៣១ ធ្នូ ១៩៩៦ |
| | -ទីប្រឹក្សាប្រចាំអង្គភាពសេដ្ឋកិច្ច គសហវ | មករា ១៩៩៥ | អភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច | ៣១ មីនា ១៩៩៧ |
| | ផ្គត់ផ្គង់ | | បែងចែកបរិក្ខារការិយាល័យ | ១៩៩៥/១៩៩៦ |
| | -បរិក្ខារការិយាល័យ | ១៩៩៥-៩៦ | | |
| ការងារគ្រប់គ្រងបំណុល : | ជ្រើសរើស/សំរាំង | | អភិវឌ្ឍន៍គ្រឿងប័ណ្ណស្ថាប័នសំរាប់ការងារគ្រប់គ្រងបំណុល | ១៩៩៥/១៩៩៦ |
| -អភិវឌ្ឍន៍គ្រឿងប័ណ្ណស្ថាប័ន សំរាប់ការងារគ្រប់គ្រងបំណុលក្រៅប្រទេស | -ជំនាញការស្ថាប័នក្នុងការងារគ្រប់គ្រង | មីនា ១៩៩៥ | រៀបចំផែនការសកម្មភាពសំរាប់របាយការណ៍បំណុលក្រៅប្រទេស | មីនា ១៩៩៥ |
| -ពង្រឹងសមត្ថភាពសំរាប់ធ្វើរបាយការណ៍បំណុលជូនធនាគារពិភពលោក | -ជំនាញការចាត់តាំង/ផែនការរួម | មិថុនា ១៩៩៥ | រៀបចំផែនការរួមសំរាប់អង្គភាពបំណុលថ្មី | ៣១ តុលា ១៩៩៥ |
| | -វិស្វករប្រព័ន្ធកុំព្យូទ័រ(CSE) | ធ្នូ ១៩៩៥ | រៀបចំកម្មវិធីបណ្តុះបណ្តាល «ក្រៅពីកុំព្យូទ័រ» សំរាប់គ្រប់គ្រងបំណុលក្រៅប្រទេស | ៣១ ធ្នូ ១៩៩៥ |
| | -អ្នកផ្គត់ផ្គង់ប្រព័ន្ធ | មិថុនា ១៩៩៥ | អនុវត្តពេញលេញចាត់តាំងថ្មី និង ផែនការបណ្តុះបណ្តាលអង្គភាពបំណុល | ៣១ ធ្នូ ១៩៩៦ |
| | | | បែងចែកប្រព័ន្ធកុំព្យូទ័រ និង បណ្តុះបណ្តាលបុគ្គលិក | ៣០ មិថុនា ១៩៩៧ |
| | | | ដើម្បីប្រើប្រាស់ និង ថែទាំ | ១៩៩៦/១៩៩៧ |
| | ផ្គត់ផ្គង់ | | (CSE) តាមដានត្រួតពិនិត្យបែងចែកប្រព័ន្ធកុំព្យូទ័រ និង បណ្តុះបណ្តាល | |
| | -បរិក្ខារការិយាល័យ | | បែងចែកបរិក្ខារការិយាល័យ | ១៩៩៥/១៩៩៧ |
| ការងារគ្រប់គ្រងបុគ្គលិក | ជ្រើសរើស : | | ដឹកនាំត្រួតពិនិត្យគណនីសហគ្រាសសាធារណៈ ដើម្បីលុបឈ្មោះនិយោជិក | ++ |
| -រួមចំណែកការកែទំរង់រដ្ឋបាល | -ក្រុមហ៊ុនពិគ្រោះ | មេសា ១៩៩៥ | ប្រមូលទិន្នន័យលើផលទុនគេហជន និង ចំណាយ | ៣១ ធ្នូ ១៩៩៥ |
| -អភិវឌ្ឍន៍យុទ្ធសាស្ត្រ សំរាប់បន្ថយទំហំក្របខ័ណ្ឌមន្ត្រីរាជការ និង ផ្នែកសហគ្រាសសាធារណៈ PE | -ទីប្រឹក្សាសហគ្រាសសាធារណៈ | មករា ១៩៩៥ | ស្នើគោលនយោបាយលាភការមន្ត្រីរាជការថ្មី | ៣០ មិថុនា ១៩៩៦ |
| | | | ផ្តល់សំណើគំរោងដំណើរការទៅរដ្ឋាភិបាល | ៣១ ធ្នូ ១៩៩៦ |
| | | | សិក្សាពីលទ្ធភាពដំណើរការ | ៣១ ធ្នូ ១៩៩៦ |
| | | | សិក្សាផែនការសោធន និង ប្រព័ន្ធធានាសង្គម | ៣០ មិថុនា ១៩៩៧ |

## កម្មវិធី ៥ «ឥ»

## ផែនការអនុវត្តគំរោង

| | | | |
|---|---|---|---|
| **ជំនួយការច្បាប់ សំរាប់អភិវឌ្ឍន៍វិស័យឯកជន**<br>–អភិវឌ្ឍន៍គន្លឹះសំខាន់ៗ មួយចំនួន នៃ.....<br>បរិយាកាសគតិយុត្ត សំរាប់<br>–ពង្រឹងសមត្ថភាពសំរាប់និពន្ធ និង<br>បណ្តុះបណ្តាល | ជ្រើសរើស :<br>–ទីប្រឹក្សាច្បាប់សំរាប់<br>–ទីប្រឹក្សាច្បាប់សំរាប់<br>–ជំនាញការច្បាប់សំរាប់សិក្សាវិនិច្ឆ័យ និងវាយតំលៃតំរូវការ<br>បណ្តុះបណ្តាល<br>–ជំនាញការច្បាប់សំរាប់និពន្ធនិងបណ្តុះបណ្តាលផែនការរួម<br>–ឯកទេសច្បាប់សំរាប់ប្រាក់កិច្ច និង យុត្តិសាស្ត្រ<br><br>–ឯកទេសស្ថាប័ន<br>**ផ្គត់ផ្គង់** :<br>បរិក្ខារការិយាល័យ និង បោះពុម្ព | បង្កើតអង្គភាពកែទំរង់គតិយុត្ត នៅក្រុមប្រឹក្សាអ្នកច្បាប់ | ៣០ មិថុនា ១៩៩៥ |
| | | អនុមតិសភាពការណ៍ជាផ្លូវការ លើច្បាប់អាទិភាពសេដ្ឋកិច្ច និង<br>ហិរញ្ញវត្ថុ | ៣១ ធ្នូ ១៩៩៥ |
| | | អនុវត្តការសិក្សាវិនិច្ឆ័យ គតិយុត្ត | ៣១ ធ្នូ ១៩៩៥ |
| | | អនុវត្តវាយតំលៃ តំរូវការបណ្តុះបណ្តាលគតិយុត្ត | ៣០ មិថុនា ១៩៩៦ |
| | | រៀបចំ-អនុវត្តរយៈពេលវែងផែនការរួមសំរាប់និពន្ធគតិយុត្តនិងបណ្តុះបណ្តាលផែនការ | ៣១ ធ្នូ ១៩៩៦ |
| | | រៀបចំ និងអនុវត្តផែនការសកម្មភាពបង្កើតរាជកិច្ចឡើងវិញ | ៣១ ធ្នូ ១៩៩៥ |
| | | រៀបចំ និង អនុវត្តផែនការសកម្មភាព បង្កើតប្រព័ន្ធលេខកូដ គតិយុត្ត | ៣១ ធ្នូ ១៩៩៦ |
| | | បង្កើតផែនការសកម្មភាព សំរាប់អភិវឌ្ឍន៍ក្របខ័ណ្ឌយុត្តិសាស្ត្រ | ៣០ មិថុនា ១៩៩៦ |
| | | បែងចែកបរិក្ខារ កុំព្យូទ័រ បោះពុម្ព និង បណ្តុះបណ្តាលបុគ្គលិក<br>ប្រើប្រាស់ និង ថែទាំបរិក្ខារទាំងនេះ | ១៩៩៥/៩៨ |
| **ការគាំទ្របច្ចេកទេសបណ្តុះបណ្តាល ផ្នែក ហិរញ្ញវត្ថុ**<br>–ផ្គត់ផ្គង់ទីកន្លែង និង បរិយាកាសសមស្រប<br>សំរាប់បណ្តុះបណ្តាល | ជ្រើសរើស :<br>–អ្នកសម្របសម្រួល បណ្តុះបណ្តាលសាងសង់ កញ្ញា ១៩៩៥<br>–សំភារៈបណ្តុះបណ្តាល ១៩៩៥ | កាត់តែងសំរបការសិក្សា និង ផែនការមេគារបណ្តុះបណ្តាល | មករា ១៩៩៥ |
| | | បញ្ចប់ការសាងសង់ បរិក្ខារបណ្តុះបណ្តាល | មករា ១៩៩៦ |
| | | រៀបចំមេរៀន បង្រៀនបុគ្គលិក | ** |
| | | តាមដានត្រួតពិនិត្យ សកម្មភាពបណ្តុះបណ្តាលរបស់អ្នកជំគ្រោះគំរោង | ** |

## កម្មវិធី ៥ «តចប់»

## ផែនការអនុវត្តគំរោង

| | | | | |
|---|---|---|---|---|
| មូលនិធិសិក្សា | ជ្រើសរើស : | | អ្នកសម្របសម្រួលជំនួយ រៀបចំវិធានគ្រប់គ្រងមូលនិធិសិក្សា | ៣០ មិថុនា ១៩៩៥ |
| សិក្សាអាទិភាពហិរញ្ញវត្ថុសកម្មភាព | ទីប្រឹក្សាសម្របសម្រួលជំនួយនៅ CDC | | រៀបចំលក្ខខណ្ឌទៅ TOR សំរាប់សិក្សាសកម្មភាព | + |
| មិនបានធ្វើអត្តសញ្ញាណកម្មច្បាស់លាស់ | | មករា ១៩៩៥ | ហិរញ្ញប្បទានដោយមូលនិធិ | |
| ពេលប្រជុំវាយតំលៃ ឬក្នុងវិស័យក្រៅគំរោង | | | ធានាការប្រើប្រាស់តាមលទ្ធភាពដ៏ល្អប្រសើរ នៃការសិក្សា | |
| អង្គភាពគ្រប់គ្រងគំរោងការ : | តែងតាំងជ្រើសរើស | | បង្កើតគណនីពិសេស នៅធនាគារជាតិនៃកម្ពុជា NBC | មករា ១៩៩៥ |
| | -អ្នកសម្របសម្រួលគំរោង | តុលា ១៩៩៤ | ប្រជុំទៀងទាត់ នៃក្រុមអនុវត្តគំរោង | ** |
| | -អភិបាលគំរោង | វិច្ឆិកា ១៩៩៤ | ចាត់ចែងសិក្ខាសាលាលើកទី ១ សំរាប់បុគ្គលិក PMU និង | ៣១ មីនា * |
| | -គណនេយ្យករគំរោង | វិច្ឆិកា ១៩៩៤ | ក្រុមនាយកគំរោងការ PCD | |
| | -ទីប្រឹក្សាគំរោង | វិច្ឆិកា ១៩៩៤ | បូកសរុបគំរោងប្រចាំឆ្នាំជាមួយធនាគារពិភពលោក | ៣១ មីនា * |
| | -បុគ្គលិក | មករា ១៩៩៥ | បូកសរុបរយៈពេលមធ្យមនៃគំរោងជាមួយធនាគារពិភពលោក | ៣០ មិថុនា ១៩៩៧ |
| | ផ្គត់ផ្គង់ : | | សុក្រឹត្យកម្មនៃកម្មវិធីការងារប្រចាំឆ្នាំ និង របាយការណ៍សន្ទុះឆ្នាំ | ៣១ ធ្នូ * |
| | -សំភារៈបរិក្ខារការិយាល័យ | | ធ្វើត្រួតពិនិត្យគណនីគំរោងប្រចាំឆ្នាំ ជូនធនាគារពិភពលោក | * |
| | -យានយន្ត | | ផ្តល់របាយការណ៍បញ្ចប់គំរោងទៅធនាគារពិភពលោក | *** |
| | | | ផ្តល់ផែនការសំរាប់ប្រតិបត្តិការគំរោងអនាគត | *** |

កំណត់សំគាល់ :កំណត់កាលបរិច្ឆេទ គឺជាកាលបរិច្ឆេទ ដែលសកម្មភាពនឹងប្រព្រឹត្តទៅ

* ប្រចាំឆ្នាំ
** ទៀងទាត់តាមតម្រូវការញឹកញាប់.
*** មិនហួស ៦ ខែ ក្រោយកាលបរិច្ឆេទបញ្ចប់ឥណទាន
+ ពេលណាត្រូវការ
++ ជាអចិន្ត្រៃយ៍